**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**លេខ** : ០០៩/១១២០/**សណ.គក**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃ[illegible]ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០២០

# សេចក្តីណែនាំ
# ស្តីពីការធ្វើបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជា

**យោង** : - សំណូមពរនៃការអនុវត្តយុទ្ធសាស្ត្ររបស់គណបក្សស្តីពី "**សមាជិកបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក**"

- សំណូមពរនៃការធ្វើបច្ចុប្បន្នភាពចំនួនសមាជិកគណបក្ស និងដើម្បីពង្រឹងការគ្រប់គ្រងទិន្នន័យសមាជិកគណបក្សប្រជាជនកម្ពុជាឲ្យមានការឯកភាពគ្នានៅក្នុងគណបក្សទាំងមូល
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២០ ។

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល** ណែនាំដល់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ និងក្រុមការងារគណបក្សចុះមូលដ្ឋានគ្រប់ថ្នាក់ អំពីការធ្វើបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជាដូចខាងក្រោម :

១- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ត្រូវចាត់ចែងរៀបចំបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជាតាមគំរូឯកភាពដូចជូនភ្ជាប់ជាមួយ ដោយត្រូវដំណើរការដូចតទៅ :

- អនុសាខាគណបក្ស និងសាខាគណបក្សត្រូវធ្វើបញ្ជីរាយនាមសមាជិកគណបក្សសម្រាប់គ្រប់គ្រងនៅថ្នាក់របស់ខ្លួន និងផ្ញើជូនគណៈកម្មាធិការគណបក្សថ្នាក់លើផ្ទាល់ ។
- គណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាគណបក្សចំណុះផ្ទាល់ថ្នាក់ក្រសួង ស្ថាប័ន ត្រូវបញ្ចូលទិន្នន័យសមាជិកស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន រៀបចំជាបញ្ជីរាយនាមសមាជិកគណបក្សសម្រាប់គ្រប់គ្រងនៅថ្នាក់របស់ខ្លួន និងផ្ញើជូនគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ។
- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ចងក្រងរៀបចំជាបញ្ជីរាយនាមសមាជិកគណបក្សសម្រាប់គ្រប់គ្រងនៅថ្នាក់របស់ខ្លួន និងផ្ញើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីបូកសរុបរាយការណ៍ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

២- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវចាត់ចែងរៀបចំបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជាតាមគំរូឯកភាពដូចជូនភ្ជាប់ជាមួយ ដោយចាប់ដំណើរការក្នុងដំណាក់កាលនៃការធ្វើបច្ចុប្បន្នភាពចំនួនសមាជិកគណបក្សប្រចាំឆ្នាំ ២០២១ តាមជំហានដូចតទៅ :

- ក្រុមបក្សនីមួយៗ ត្រូវផ្អែកលើទិន្នន័យបញ្ជីរាយនាមសមាជិកក្រុមបក្ស និងសៀវភៅគ្រួសារបក្ស ដើម្បីពិនិត្យផ្ទៀងផ្ទាត់សរសេរបំពេញទិន្នន័យលើបញ្ជីរាយនាមសមាជិកគណបក្ស(តាមគំរូឯកភាព) ផ្ញើជូនអនុសាខា និងសាខាគណបក្ស ។

- សាខាគណបក្សថតចម្លងចងក្រងបញ្ជីរាយនាមសមាជិកគណបក្សសម្រាប់គ្រប់គ្រងនៅថ្នាក់របស់ខ្លួន និងផ្ញើជូនគណៈកម្មាធិការគណបក្សឃុំ សង្កាត់ ឬគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

- គណៈកម្មាធិការគណបក្សឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវបូកសរុបធ្វើរបាយការណ៍ស្ថិតិសមាជិកគណបក្សស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ផ្ញើជូនគណៈកម្មាធិការគណបក្សថ្នាក់លើផ្ទាល់ ។ ទន្ទឹមនេះ ត្រូវចាត់ចែងវាយកុំព្យូទ័របញ្ចូលទិន្នន័យសមាជិក ដើម្បីរៀបចំជាបញ្ជីសមាជិកគណបក្សសម្រាប់គ្រប់គ្រងនៅថ្នាក់របស់ខ្លួន ស្របតាមលទ្ធភាពជាក់ស្តែងនៃមូលដ្ឋាននីមួយៗ ។

- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត និងគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបធ្វើរបាយការណ៍ស្ថិតិសមាជិកគណបក្សស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយមានទិន្នន័យចំនួនសមាជិកគណបក្សចាប់ពីថ្នាក់ឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

- គណៈកម្មាធិការគណបក្សរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍ស្ថិតិសមាជិកគណបក្ស មកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីបូកសរុបរាយការណ៍ជូនគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។ ទន្ទឹមនេះ ត្រូវមានផែនការដឹកនាំសម្រេចឲ្យបានការបញ្ចូលទិន្នន័យសមាជិក ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងបញ្ជីសមាជិកគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យានៅពេលខាងមុខ ។

៣- ក្រុមការងារគណបក្សចុះមូលដ្ឋានគ្រប់ថ្នាក់ មានភារកិច្ចចូលរួមសហការ និងជួយគាំទ្រដល់គណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ក្នុងការរៀបចំធ្វើបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជាឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

៤- ក្រុមការងារគណបក្សចុះមូលដ្ឋាន និងគណៈកម្មាធិការគណបក្សគ្រប់ថ្នាក់ត្រូវយកចិត្តទុកដាក់ដឹកនាំកម្លាំងយុវជនរបស់គណបក្ស ចូលរួមឲ្យបានសកម្មក្នុងការធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជានេះ ។

៥- គណៈកម្មាធិការត្រួតពិនិត្យគណបក្សគ្រប់ថ្នាក់ មានភារកិច្ចជួយគណៈកម្មាធិការគណបក្សក្នុងការតាមដានត្រួតពិនិត្យដំណើរការអនុវត្តការងារធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជានេះ ។

៦- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល មានភារកិច្ចរៀបចំគំរូបញ្ជីរាយនាមសមាជិកគណបក្សប្រជាជនកម្ពុជា តារាងស្ថិតិសមាជិកគណបក្សប្រជាជនកម្ពុជា និងផ្សព្វផ្សាយណែនាំការងារជាក់ស្តែង ជូនគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។

ទទួលបានសេចក្តីណែនាំនេះ **សម្តេច ឯកឧត្តម លោកជំទាវ** ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានរាជធានី ខេត្ត ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងស្ថាប័នគណបក្សដែលពាក់ព័ន្ធត្រូវចាត់ចែងអនុវត្តឲ្យទទួលបានលទ្ធផលល្អប្រសើរ ។

**ជ. គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ ០០១/០១២៥/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃ សៅរ៍ ៥រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

**យោង** : - ស្មារតីនៃមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស ពីថ្ងៃទី ៣០ ខែមករា ដល់ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៥ អំពីយុទ្ធសាស្ត្រ "ផ្អែកលើអំពើល្អរបស់មន្ត្រីគណបក្ស គុណភាព និងបរិមាណសមាជិកគណបក្ស ដើម្បីឈ្នះឆ្នោត"

- សេចក្តីណែនាំលេខ ២០/១៧ សណ.គក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីវិធានការមួយចំនួនសម្រាប់អនុវត្តយុទ្ធសាស្ត្រ "សមាជិកគណបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក"
- សេក្តីណែនាំលេខ ០០៩/១១២០ សណ.គក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្តិពីការធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជា
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២៥

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល**ណែនាំអំពីវិធានការមួយចំនួនសម្រាប់អនុវត្តការងារគ្រប់គ្រងបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា ដូចខាងក្រោមៈ

១- បញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជានៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ទាំងអស់ និងនៅក្រៅប្រទេស ត្រូវបានបញ្ចូលមកក្នុងប្រព័ន្ធ Server រៀបចំជាបញ្ជីសមាជិកគណបក្សតែមួយគ្រប់គ្រងដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលរួចហើយ ។ បញ្ជីសមាជិកគណបក្សនៅក្នុងប្រព័ន្ធ Server ត្រូវបានផ្ទៀងផ្ទាត់ទិន្នន័យជាមួយបញ្ជីបោះឆ្នោត ដើម្បីធានាថាសមាជិកគណបក្សមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានទិន្នន័យត្រឹមត្រូវដូចក្នុងអត្តសញ្ញាណប័ណ្ណ និងក្នុងបញ្ជីបោះឆ្នោត គ្មានឈ្មោះស្ទួន ដែលបានបង្កលក្ខណសម្បត្តិងាយស្រួល និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្សឆ្ពោះទៅកាន់ការបោះឆ្នោត ។

បញ្ជីមន្ត្រីគណបក្សនៅគ្រប់ថ្នាក់ ក៏ត្រូវបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ Server សម្រេចបានជាមូលដ្ឋានរួចហើយ ដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីគណបក្សតាមគោលការណ៍ណែនាំឯកភាព មានទិន្នន័យច្បាស់លាស់ ពិតប្រាកដ និងចងក្រងរក្សាទុកឯកសារពាក់ព័ន្ធមន្ត្រីគណបក្ស ។

២- ទិន្នន័យសមាជិកគណបក្សដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ Server ត្រូវមានលក្ខណសម្បត្តិស្របតាមមាត្រាទី ៥ ជំពូក III នៃលក្ខន្តិកៈគណបក្ស និងត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៣- ត្រូវបញ្ចូលទិន្នន័យមន្ត្រីគណបក្សទាំងអស់ទៅក្នុងប្រព័ន្ធ Server ដើម្បីគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា និងប្រើប្រាស់សម្រាប់ការពិនិត្យវាយតម្លៃរៀបចំមន្ត្រី និងការរៀបចំបញ្ជីបេក្ខជនរបស់គណបក្ស ។

៤- ត្រូវបន្តជំរុញការបោះពុម្ពប័ណ្ណសមាជិកគណបក្ស តាមទិន្នន័យចេញពីបញ្ជីសមាជិកគណបក្ស ក្នុងប្រព័ន្ធ Server ចែកជូនផ្ទាល់ដល់សមាជិកគណបក្សទាំងអស់នៅមូលដ្ឋាន ដើម្បីត្រួតពិនិត្យវត្តមានសមាជិកគណបក្សជាអ្នកគាំទ្រគណបក្សពិតប្រាកដ និងបន្តកសាងពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្ស ឆ្ពោះទៅកាន់ការបោះឆ្នោតនាពេលខាងមុខ ។ បញ្ចប់ការចេញប័ណ្ណសមាជិកគណបក្សដោយគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៥- ត្រូវបន្តរៀបចំការផ្តល់ប័ណ្ណមន្ត្រីគណបក្សតាមទិន្នន័យចេញពីប្រព័ន្ធ Server ដើម្បីត្រួតពិនិត្យពង្រឹងការគ្រប់គ្រងមន្ត្រីគណបក្ស ជាពិសេសចំពោះមន្ត្រីនយោបាយ និងមន្ត្រីគ្រប់គ្រងដោយថ្នាក់កណ្តាល ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**

**ប្រធាន**

**ហ៊ុន សែន**

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល
គណៈចាត់តាំង

ព្រះរាជាណាចក្រកម្ពុជា
ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ២០១៦

# ជំនួយស្មារតី
# ស្តីពីការបញ្ចូលសមាជិកគណបក្ស

យោងលក្ខន្តិកៈគណបក្ស និងគោលការណ៍ណែនាំនានារបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ការបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជាត្រូវបានកំណត់ដូចខាងក្រោម :

## I- <u>គោលការណ៍កំណត់នៃច្បាប់ស្តីអំពីគណបក្សនយោបាយ ជំពូកទី៣</u>

- ប្រជាពលរដ្ឋខ្មែរដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ និងមានសិទ្ធិពលរដ្ឋអាចចូលជាសមាជិកគណបក្សនយោបាយបាន ។
- ការចូលជាសមាជិកគណបក្សនយោបាយ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ។
- សមាជិកគណបក្សនយោបាយ អាចលាឈប់ពីគណបក្សនយោបាយបានគ្រប់ពេលវេលា ដោយមិនចាំបាច់បញ្ជាក់ពីមូលហេតុឡើយ ។
- ប្រជាពលរដ្ឋខ្មែរម្នាក់ មិនអាចជាសមាជិកគណបក្សនយោបាយលើសពីមួយក្នុងពេលតែមួយបានទេ ។ ក្នុងករណីដែលបុគ្គលមួយរូបចូលរួមជាសមាជិកគណបក្សនយោបាយនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ ។
- បុព្វជិត មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ និងកងកម្លាំងនគរបាលជាតិ អាចចូលរួមជាសមាជិកគណបក្សនយោបាយបាន តែមិនត្រូវធ្វើសកម្មភាពគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយឡើយ ។

## II- <u>លក្ខណសម្បត្តិចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា</u>

លក្ខន្តិកៈគណបក្ស ជំពូក III មាត្រាទី ៥ ចែងអំពីលក្ខណសម្បត្តិចូលជាសមាជិក រួមមាន :

១- ពលរដ្ឋកម្ពុជាទាំងពីរភេទ ដែលមានអាយុ ១៨ឆ្នាំឡើងទៅ អាចចូលជាសមាជិកគណបក្សបាន ។

២- មានឧត្តមគតិស្នេហាជាតិមាតុភូមិ និងលទ្ធិប្រជាធិបតេយ្យ គាំទ្រកម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់គណបក្ស ។

៣- មានគុណធម៌ និងទំនាក់ទំនងល្អជាមួយប្រជាជន ហើយត្រូវបានប្រជាជនស្រឡាញ់រាប់អាន ជឿទុកចិត្ត ។

៤- មិនមែនជាសមាជិកគណបក្សនយោបាយដទៃ ។

## III- <u>ទម្រង់បែបបទបញ្ចូលសមាជិកគណបក្ស</u>

១- សាមីខ្លួនធ្វើពាក្យសុំចូលជាសមាជិកគណបក្ស ដោយភ្ជាប់ជាមួយជីវប្រវត្តិ ។

២- មានសមាជិកគណបក្ស ២នាក់ជាអ្នកឧទ្ទេសនាម ។ អ្នកឧទ្ទេសនាមគឺជាសមាជិកគណបក្ស ដែលរួមការងារជាមួយ ឬបានរស់នៅមូលដ្ឋានជាមួយអ្នកសុំចូលជាសមាជិកគណបក្ស ហើយជាអ្នកជានាដឹងឮ អំពីជីវប្រវត្តិ សកម្មភាព និងលក្ខណសម្បត្តិរបស់អ្នកសុំចូលជាសមាជិកគណបក្ស ។

៣- គណៈកម្មាធិការសាខាគណបក្ស ពិនិត្យសំណុំបែបបទសុំចូលជាសមាជិកគណបក្សម្នាក់ៗ ហើយធ្វើបញ្ជីរួមរាយការណ៍ជូនគណៈកម្មាធិការគណបក្សថ្នាក់លើ ។

៤- គណៈកម្មាធិការគណបក្សដែលដឹកនាំគ្រប់គ្រងផ្ទាល់សាខាគណបក្ស ពិនិត្យ និងចេញសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ហើយស្នើសុំគណៈកម្មាធិការគណបក្ស ក្រសួង ស្ថាប័ន រាជធានី ខេត្ត ផ្តល់ប័ណ្ណសម្គាល់សមាជិកគណបក្ស ។

៥- ចាត់តាំងពិធីបញ្ចូលសមាជិកគណបក្សថ្មីនៅសាខាគណបក្ស ។

## IV- ការបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស

១- អនុវត្តតាមស្មារតីនៃសេចក្តីណែនាំលេខ ៣៧ សណ.គក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីការគ្រប់គ្រងសមាជិកគណបក្សក្នុងករណីពិសេស ចំពោះការសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា របស់ឥស្សរជនដែលមានឥទ្ធិពលក្នុងសង្គម មន្ត្រីជាន់ខ្ពស់នៃគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ព្រឹទ្ធសភា ចាប់ពីថ្នាក់សមាជិកគណៈកម្មាធិការនាយកឡើងទៅ នាយទាហានជាន់ខ្ពស់ នាយនគរបាលជាន់ខ្ពស់ និងមន្ត្រីដែលជាសមាជិកគណបក្សនយោបាយនានា ចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែល នៅក្រសួង ស្ថាប័ន និងចាប់ពីថ្នាក់ប្រធានមន្ទីរ ឬថ្នាក់ប្រហាក់ប្រហែលនៅរាជធានី ខេត្ត ត្រូវបានពិនិត្យសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

២- គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលប្រគល់សិទ្ធិជូនគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ពិនិត្យសម្រេចបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេសចំពោះអ្នកដែលមានឋានៈនាទីត្រឹមប្រធានការិយាល័យចុះ ឬថ្នាក់ប្រហាក់ប្រហែល នៅក្រសួង ស្ថាប័ន និងថ្នាក់អនុប្រធានមន្ទីរចុះ ឬថ្នាក់ប្រហាក់ប្រហែលនៅរាជធានី ខេត្ត ។

៣- សាមីខ្លួនត្រូវបំពេញបែបបទធ្វើពាក្យសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាដោយភ្ជាប់ជាមួយ ជីវប្រវត្តិ ពាក្យសុំលាលែងពីគណបក្សនយោបាយចាស់ និងមានសមាជិកគណបក្ស ២ នាក់ជាអ្នកឧទ្ទេសនាម និងជានាដឹងឮអំពីជីវប្រវត្តិ សកម្មភាព និងលក្ខណសម្បត្តិរបស់ខ្លួន ។

៤- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មានភារកិច្ចរៀបចំពិធីបញ្ចូលសមាជិកគណបក្សក្នុងករណីពិសេស ។

៥- សមាជិកគណបក្សក្នុងករណីពិសេស ត្រូវបានរៀបចំឲ្យចូលរួមជីវភាពបក្សនៅក្នុងសាខាពិសេស ឬក្រុមសមាជិកដែលស្ថិតក្រោមការគ្រប់គ្រងដឹកនាំផ្ទាល់របស់ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬនៅតាមសាខាគណបក្សនានាស្របតាមសំណូមពរការងារ និងសភាពការណ៍ជាក់ស្តែង ។

សមាជិកគណបក្សក្នុងករណីពិសេសមិនអាចចូលរួមជីវភាពជាមួយគណបក្សដទៃទៀយ បើសិនជាគ្មានការចាត់តាំងប្រគល់ភារកិច្ចពីគណបក្ស ។

## V- **ពិធីបញ្ចូលសមាជិកគណបក្សប្រជាជនកម្ពុជា**

អនុវត្តតាមកម្មវិធី :

១- ប្រកាសហេតុ

២ ឧទ្ទេសនាមគណៈអធិបតី ភ្ញៀវកិត្តិយស និងសមាជិកអញ្ជើញចូលរួម

៣- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងគោរពទង់គណបក្ស

៤- សមាជិកថ្មី អានពាក្យសុំចូលជាសមាជិកគណបក្សប្រជាជនកម្ពុជា

៥- មន្ត្រីទទួលបន្ទុកការងារចាត់តាំងអានសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស

៦- គណៈអធិបតីប្រគល់សេចក្តីសម្រេច

៧- ចំណាប់អារម្មណ៍ និងការប្តេជ្ញាចិត្តរបស់សមាជិកថ្មី

៨- មតិរបស់ប្រធានសាខាគណបក្ស (បើសិនចាំបាច់)

៩- មតិសំណេះសំណាល និងផ្តាំផ្ញើរបស់គណៈអធិបតី

១០-គោរពទង់គណបក្សបិទកម្មវិធី ។

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០១៧

# ជំនួយស្មារតី
# ស្តីពីការអនុវត្តគោលការណ៍មួយចំនួននៃការងារគ្រប់គ្រងសមាជិកគណបក្ស

យោងលក្ខន្តិកៈគណបក្ស សេចក្តីណែនាំលេខ ២០ សណ.គក ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងសមាជិកគណបក្ស និងគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ក្នុងការងារគ្រប់គ្រងសមាជិកគណបក្សត្រូវយកចិត្តទុកដាក់អនុវត្តនូវគោលការណ៍មួយចំនួនដូចខាងក្រោម :

## I. **អំពីគោលការណ៍រួម**

- សមាជិកគណបក្សម្នាក់ៗ ដែលបានចូលជាសមាជិកគណបក្សប្រជាជនកម្ពុជាត្រូវបានទទួលសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស និងត្រូវបានផ្តល់ប័ណ្ណសម្គាល់សមាជិកគណបក្ស ។

- គណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាគណបក្សត្រូវមានបញ្ជីរាយនាមសមាជិកគណបក្ស និងបញ្ជីស្ថិតិសមាជិកគណបក្ស សម្រាប់ការគ្រប់គ្រងសមាជិកគណបក្សនៅថ្នាក់របស់ខ្លួន និងរាយការណ៍ជូនអង្គការចាត់តាំងគណបក្សថ្នាក់លើ ។

- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់កណ្តាល ត្រូវមានបញ្ជីស្ថិតិសមាជិក និងអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួន និងត្រូវចងក្រងបញ្ជីរាយនាមសមាជិកគណបក្ស សម្រាប់ការគ្រប់គ្រងសមាជិកគណបក្សផង និងការតាមដានបង្កលក្ខណៈជួយសម្រួលដល់សមាជិកគណបក្សក្នុងការចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោតផង ។ ទន្ទឹមនេះ ត្រូវមានបញ្ជីរាយនាមសមាសភាពថ្នាក់ដឹកនាំគណបក្ស និងរៀបចំគ្រប់គ្រងជីវប្រវត្តិសង្ខេបរបស់មន្ត្រីគណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន ។

- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បានរៀបចំតារាងគំរូមួយចំនួនដើម្បីស្នើសុំគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះថ្នាក់កណ្តាលបំពេញទិន្នន័យ សម្រាប់បូកសរុបរាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ លើមូលដ្ឋានតារាងគំរូនេះ អាចបំពេញបន្ថែមខ្លឹមសារផ្សេងទៀតសម្រាប់ការវិភាគទិន្នន័យតាមការចាំបាច់ ។ បញ្ជីស្ថិតិអង្គការចាត់តាំង និងសមាជិកគណបក្ស ត្រូវធ្វើប្រចាំត្រីមាសផ្ញើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ត្រឹមថ្ងៃទី ២៨ នៃខែមីនា ខែមិថុនា ខែកញ្ញា និងខែធ្នូ ។

- ដោយឡែក ការតែងតាំងមន្ត្រីគណបក្ស និងការចាត់តាំងប្រគល់ភារកិច្ចការងារគណបក្ស អនុវត្តបានតែចំពោះមន្ត្រីគណបក្សដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមគោលការណ៍កំណត់ និងជាសមាជិកគណបក្សប្រជាជនកម្ពុជា ដោយមានឯកសារបញ្ជាក់ថ្ងៃខែឆ្នាំចូលជាសមាជិកគណបក្ស ។

## II. អំពីការផ្ទេរជីវភាពគណបក្ស

- មាត្រាទី ៩ នៃលក្ខន្តិកៈគណបក្សចែងថា : "សមាជិកណាមិនបានចូលរួមប្រជុំជីវភាព ឬក៏មិនបង់ភាគទានជូនគណបក្សចំនួន ៣ដងជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មាធិការសាខាគណបក្សសម្រេចលុបឈ្មោះចេញពីសមាជិក ហើយរាយការណ៍ឡើងថ្នាក់លើពិនិត្យសម្រេច ។ ការផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតរបស់សមាជិក ត្រូវតែមានការផ្ទេរជីវភាពគណបក្ស ។"

- អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ ត្រូវអនុវត្តរបបប្រជុំជីវភាពគណបក្សយ៉ាងតិច ១ខែម្តងស្របតាមគោលការណ៍កំណត់ ។ យោងតាមមាត្រាទី ៩ នៃលក្ខន្តិកៈគណបក្ស អង្គការចាត់តាំងគណបក្ស និងសមាជិកគណបក្ស មិនអាចខកខានមិនបានប្រជុំជីវភាពគណបក្សរយៈពេល ៣ខែដោយគ្មានមូលហេតុបានឡើយ ។

- ករណីដែលមន្ត្រី សមាជិកគណបក្ស ត្រូវបានចាត់តាំងឲ្យទៅបំពេញភារកិច្ច ឬបេសកកម្មនៅកន្លែងណាមួយ (ដែលមានសមាសភាពចម្រុះមកពីអង្គការចាត់តាំងគណបក្សនានា) ក្នុងរយៈពេលតិចជាង ៣ខែ គឺអាចប្រើប្រាស់ប័ណ្ណសម្គាល់សមាជិកគណបក្សដើម្បីចូលរួមប្រជុំជីវភាពគណបក្សនៅកន្លែងនោះ ដោយមិនចាំបាច់ធ្វើលិខិតឧទ្ទេសនាមជីវភាពគណបក្សទេ ។

- ករណីដែលមន្ត្រី សមាជិកគណបក្ស ត្រូវបានផ្លាស់ប្តូរភារកិច្ចពីស្ថាប័ន អង្គភាពមួយ ទៅស្ថាប័នអង្គភាពមួយទៀត ឬផ្ទេរពីមូលដ្ឋានមួយ ទៅមូលដ្ឋានមួយទៀត នៅក្នុងអង្គការចាត់តាំងគណបក្សមូលដ្ឋានតែមួយ គឺត្រូវធ្វើលិខិតឧទ្ទេសនាមជីវភាពគណបក្ស ដោយផ្ទេរជីវភាពពីសាខាគណបក្សដែលផ្ទេរចេញ ជូនទៅសាខាគណបក្សទទួលឲ្យចូលរួមជីវភាព ចុះហត្ថលេខាដោយប្រធានសាខាគណបក្ស ។ម្យ៉ាងទៀត អាចយោងតាមសេចក្តីសម្រេចផ្ទេរ តែងតាំង ផ្លាស់ប្តូរភារកិច្ចមន្ត្រីធ្វើជាមូលដ្ឋានដើម្បីលុបឈ្មោះសាមីខ្លួនពីបញ្ជីសមាជិកគណបក្សនៃសាខាគណបក្សផ្ទេរចេញ និងចុះឈ្មោះក្នុងបញ្ជីសមាជិកគណបក្សនៃសាខាគណបក្សទទួលឲ្យចូលរួមជីវភាព ។

- ករណីដែលមន្ត្រី សមាជិកគណបក្ស ត្រូវបានផ្លាស់ប្តូរភារកិច្ច ផ្ទេរពីស្ថាប័ន អង្គភាពមួយ ទៅស្ថាប័នអង្គភាពមួយទៀត ឬផ្ទេរពីមូលដ្ឋានមួយ ទៅមូលដ្ឋានមួយទៀត ឬត្រូវបានចូលនិវត្តន៍ទៅរស់នៅឯមូលដ្ឋានដែលមិនស្ថិតនៅក្នុងអង្គការចាត់តាំងគណបក្សមូលដ្ឋានតែមួយ គឺត្រូវធ្វើលិខិតឧទ្ទេសនាមជីវភាពគណបក្សដោយគណៈកម្មាធិការគណបក្សមូលដ្ឋាន ឬគណៈកម្មាធិការគណបក្សដែលគ្រប់គ្រងផ្ទាល់ ជូនទៅអង្គការចាត់តាំងគណបក្សដែលត្រូវទទួលរៀបចំឲ្យសាមីខ្លួនចូលរួមជីវភាពនៅសាខាគណបក្សចំណុះរបស់ខ្លួន ។ ករណីដែលការផ្ទេរជីវភាពគណបក្សចេញពីគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវមានការបញ្ជាក់ដោយគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ឬគណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ។

ការផ្ទេរជីវភាពសមាជិកគណបក្សដែលមានតួនាទីជាមន្ត្រីគណបក្ស ត្រូវចម្លងជូនភ្ជាប់ជាមួយនូវជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានចុះហត្ថលេខា និងបោះត្រាបញ្ជាក់ដោយគណៈកម្មាធិការគណបក្ស ។

ការផ្ទេរជីវភាពគណបក្ស របស់មន្ត្រីជាថ្នាក់ដឹកនាំនៃអង្គការចាត់តាំងគណបក្ស គឺដើម្បីឲ្យទៅចូលរួមជីវភាពគណបក្សនៅកន្លែងដែលសាមីខ្លួនត្រូវបំពេញភារកិច្ច ឬរស់នៅប៉ុណ្ណោះ មិនអាចផ្ទេរឲ្យទៅទទួលតួនាទីជាថ្នាក់ដឹកនាំនៃអង្គការចាត់តាំងគណបក្សនោះឡើយ ព្រោះការរៀបចំមន្ត្រីដឹកនាំនៃអង្គការចាត់តាំងគណបក្ស

គ្រប់ថ្នាក់ត្រូវអនុវត្តស្របតាមមាត្រាទី ១០ នៃលក្ខន្តិកៈគណបក្ស និងគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។

- ចំពោះសមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្រ ត្រូវបានគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលឧទ្ទេសនាមឲ្យចូលរួមជីវភាពគណបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួន ។

- ដោយឡែកចំពោះលិខិតឧទ្ទេសនាមជីវភាពគណបក្សមានបិទរូបថត (បត់ជា ៤ទំព័រ ទំហំ ៧ស.ម x ១០ស.ម) ដែលបានដាក់ឲ្យប្រើប្រាស់តាំងពីខែតុលា ឆ្នាំ ១៩៩៥ មក នៅមានសុពលភាពប្រើប្រាស់បន្ត ។ ប៉ុន្តែក្នុងសភាពការណ៍បច្ចុប្បន្ននេះ អនុញ្ញាតឲ្យប្រើប្រាស់សម្រាប់តែការផ្ទេរជីវភាពសមាជិកគណបក្សដែលត្រូវបានសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្សដោយគណៈកម្មាធិការគណបក្សថ្នាក់ខ្លួនផ្ទាល់តែប៉ុណ្ណោះ ។

## III. អំពីការបង់វិភាគទានគណបក្ស

ការបង់វិភាគទានគណបក្ស និងឧបត្ថម្ភថវិកាជូនគណបក្ស គឺជាការសម្តែងនូវឆន្ទៈ និងមនោសញ្ចេតនាស្មោះស្ម័គ្រចំពោះគណបក្ស ។ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល បានកំណត់ជាគោលការណ៍អំពីការបង់វិភាគទានគណបក្សប្រចាំខែដូចខាងក្រោម :

- សមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្របង់វិភាគទានប្រចាំខែ ៣០០.០០០រៀល ។

- មន្ត្រីជាន់ខ្ពស់របស់គណបក្សដែលមានឋានៈចាប់ពីស្មើអនុរដ្ឋលេខាធិការឡើង បង់វិភាគទាន ៥% នៃបៀវត្ស ។

- មន្ត្រីដែលមានបៀវត្សផ្សេងទៀត បង់ភាគទានភ្ជាប់និស្ស័យប្រចាំខែ ២០០រៀល និងបំផុសសមាជិកគណបក្សដែលមានលទ្ធភាពឧបត្ថម្ភថវិកាជូនគណបក្ស ។ ចំពោះសមាជិកគណបក្សជាប្រជាជន គឺមិនតម្រូវឲ្យបង់ភាគទានគណបក្សទេ ។

- វិភាគទានប្រចាំខែនៃមន្ត្រីជាន់ខ្ពស់ត្រូវបង់ចូលថវិកាថ្នាក់កណ្តាល (គណៈកម្មាធិការហិរញ្ញវត្ថុ) ។ ភាគទានភ្ជាប់និស្ស័យរបស់សមាជិកគណបក្សត្រូវបង់ ៥០% ចូលថវិកាថ្នាក់កណ្តាល និងរក្សាទុក ៥០% សម្រាប់ប្រើប្រាស់នៅក្នុងសាខាគណបក្ស ។

ការបង់ភាគទានភ្ជាប់និស្ស័យត្រូវអនុវត្តទន្ទឹមនឹងការប្រជុំជីវភាពគណបក្ស ។ សមាជិកម្នាក់ៗមានកាតព្វកិច្ចបង់ភាគទានគណបក្សប្រចាំខែ ២០០រៀល ជូនសាខាគណបក្សតាមគោលការណ៍កំណត់ ហើយសាខាគណបក្សនីមួយៗអាចពិនិត្យកំណត់កម្រិតភាគទានភ្ជាប់និស្ស័យសមស្រប ដោយយោងតាមការស្ម័គ្រចិត្ត និងលទ្ធភាពរបស់សមាជិកគណបក្ស ។

## IV. អំពីឯកសារបញ្ជាក់ទទួលស្គាល់ជាសមាជិកគណបក្សប្រជាជនកម្ពុជា

សេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស និងប័ណ្ណសម្គាល់សមាជិកគណបក្ស មានចុះថ្ងៃខែឆ្នាំចូលគណបក្សដែលត្រូវបានគិតជាអាយុបក្សរបស់សមាជិកគណបក្សម្នាក់ៗ ។ យោងតាមលក្ខន្តិកៈចាស់របស់គណបក្ស អាយុបក្សត្រូវបានគិតពីថ្ងៃដែលគណៈកម្មាធិការគណបក្សសម្រេចយល់ព្រមទទួលស្គាល់ជាបក្ខជនពេញសិទ្ធិ ។ មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស បានអនុម័តលក្ខន្តិកៈកែប្រែថ្មី

នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ ១៩៩១ ដែលចែងអំពីសមាជិកគណបក្ស ដោយមិនមានបែងចែកជាបក្ខជនត្រៀម និងបក្ខជនពេញសិទ្ធិទៀតទេ ។ ដូច្នេះបក្ខជនត្រៀម បានក្លាយជាសមាជិកគណបក្ស ដោយគិតថ្ងៃចូលគណបក្ស នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ ១៩៩១ ។

រយៈពេលកន្លងមក មានមន្ត្រី សមាជិកគណបក្សជាច្រើនបានផ្លាស់ប្តូរភារកិច្ច ផ្លាស់ប្តូរស្ថាប័ន អង្គភាព កន្លែងធ្វើការ ផ្លាស់ប្តូរទីលំនៅ ដោយមួយចំនួនពុំមានការផ្ទេរជីវភាពគណបក្សឲ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ នាំឲ្យដាច់ការប្រជុំជីវភាពជាច្រើនខែ ឃ្លាតឆ្ងាយពីការដឹកនាំរបស់គណបក្ស ។

ក្នុងករណីនេះ បើសាមីខ្លួនអះអាងថាខ្លួនជាសមាជិកគណបក្ស និងស្នើសុំចូលរួមជីវភាពគណបក្ស ហើយអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្សនៅទីនោះបានពិនិត្យឃើញថាសាមីខ្លួនមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមានឯកសារបញ្ជាក់ពីអតីតភាពជាសមាជិកគណបក្ស គណៈកម្មាធិការគណបក្សត្រូវពិនិត្យសម្រេចទទួលស្គាល់ជាសមាជិកគណបក្ស ហើយចុះឈ្មោះក្នុងបញ្ជីសមាជិកគណបក្ស និងរៀបចំឲ្យចូលរួមជីវភាពគណបក្សនៅក្នុងសាខាគណបក្សចំណុះរបស់ខ្លួន ។ សាមីខ្លួនត្រូវបង្ហាញនូវឯកសារបញ្ជាក់ពីអតីតភាពជាសមាជិកគណបក្សរបស់ខ្លួនដូចខាងក្រោម :

- ប័ណ្ណសម្គាល់សមាជិកគណបក្ស
- សេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ឬសេចក្តីសម្រេចយល់ព្រមបញ្ចូលបក្ខជន
- សេចក្តីសម្រេចយល់ព្រមទទួលស្គាល់ជាបក្ខជនពេញសិទ្ធិ
- លិខិតឧទ្ទេសនាមជីវភាពគណបក្ស
- សេចក្តីសម្រេចតែងតាំង ឬចាត់តាំង ប្រគល់ភារកិច្ចការងារគណបក្ស
- ប័ណ្ណ ឬលិខិតសម្គាល់ខ្លួនមន្ត្រីបុគ្គលិកស្ថាប័នគណបក្ស
- លិខិតបញ្ជាក់របស់គណៈកម្មាធិការគណបក្សដែលសាមីខ្លួនធ្លាប់បានចូលរួមជីវភាពគណបក្ស ដោយមានសមាជិកគណបក្ស ២រូបនៅក្នុងអង្គការចាត់តាំងគណបក្សនៅទីនោះជាអ្នកជានាដឹងឮ ។

គណៈកម្មាធិការគណបក្ស ត្រូវពិនិត្យសម្រេចអំពីការទទួលស្គាល់ជាសមាជិកគណបក្ស និងចុះថ្ងៃខែឆ្នាំចូលគណបក្សរបស់សាមីខ្លួនដែលបានស្នើសុំ យោងតាមឯកសារបញ្ជាក់ដោយអង្គការចាត់តាំងគណបក្សដែលសាមីខ្លួនបានបង្ហាញជូន ។ ក្នុងករណីដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងឯកសារដើម្បីទទួលស្គាល់ជាសមាជិកគណបក្សបាន ត្រូវណែនាំសាមីខ្លួនបំពេញបែបបទដើម្បីពិនិត្យបញ្ចូលសមាជិកគណបក្សថ្មី ។

<u>**បញ្ជាក់**</u> : សាមីខ្លួនដែលបាត់រាល់ឯកសារបញ្ជាក់ជាសមាជិកគណបក្សប្រជាជនកម្ពុជា ត្រូវធ្វើពាក្យសុំបញ្ជាក់ដោយគណៈកម្មាធិការគណបក្សដែលបានចេញសេចក្តីសម្រេចយល់ព្រមបញ្ចូលសមាជិកគណបក្ស ឬធ្វើពាក្យសុំបញ្ជាក់ដោយគណៈកម្មាធិការគណបក្សដែលបានគ្រប់គ្រងជីវភាពគណបក្សរបស់ខ្លួនពីមុន អំពីការចូលរួមជីវភាពគណបក្សរបស់ខ្លួន និងអំពីថ្ងៃខែឆ្នាំចូលគណបក្សផង បើមានឯកសារគ្រប់គ្រងនៅក្នុងអង្គការចាត់តាំងគណបក្សនោះ ។

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

គណៈចាត់តាំង

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃពុធ ១០រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៨

# ជំនួយស្មារតី
# ស្តីពីការឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ជាកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីនៅក្នុងអង្គការតុលាការ

យោងលក្ខន្តិកៈគណបក្ស និងសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ស្តីពីការគ្រប់គ្រងសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីនៅក្នុងអង្គការតុលាការ

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្នើគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សគ្រប់ថ្នាក់ យកចិត្តទុកដាក់អនុវត្តការឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដើម្បីរៀបចំឲ្យសមាជិកគណបក្សជាកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ និងមន្ត្រីនៅក្នុងអង្គការតុលាការ បានចូលរួមជីវភាពគណបក្សស្របតាមលក្ខន្តិកៈគណបក្ស តាមទម្រង់បែបបទដូចខាងក្រោម :

១. <u>ការឧទ្ទេសនាមផ្ទេរសមាជិកគណបក្សពីគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ទៅគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់ក្រោម</u> :

ត្រូវធ្វើលិខិតឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដោយមានចុះហត្ថលេខា និងបោះត្រារបស់គណៈកម្មការ ក.២៦ ឬ ក.២៧ ឬ ក.១៨ ផ្ញើជូនគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សដែលសាមីខ្លួនត្រូវបានផ្ទេរភារកិច្ចទៅបម្រើការងារនៅទីនោះ ។

២. <u>ការឧទ្ទេសនាមផ្ទេរសមាជិកគណបក្សពីអនុគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សមួយ ទៅអនុគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សមួយទៀត ឬទៅគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ</u> :

ត្រូវធ្វើលិខិតឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដោយមានចុះហត្ថលេខាប្រធានអនុគណៈកម្មការ និងមានការបញ្ជាក់ចុះហត្ថលេខា និងបោះត្រាគណៈកម្មការ ក.២៦ ផ្ញើជូនអនុគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មការ ក.២៦ ឬផ្ញើជូនគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនត្រូវបានផ្ទេរភារកិច្ចទៅបម្រើការងារនៅទីនោះ ។

៣. ការឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ពីគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល :

ត្រូវធ្វើលិខិតឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដោយមានចុះហត្ថលេខាប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានការបញ្ជាក់ចុះហត្ថលេខា និងបោះត្រាគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ញើជូនគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ឬអនុគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សដែលសាមីខ្លួនត្រូវបានផ្ទេរភារកិច្ចទៅបម្រើការងារនៅទីនោះ ។

៤. ការឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ពីគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយ ទៅគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមួយផ្សេងទៀត :

ត្រូវធ្វើលិខិតឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដោយមានចុះហត្ថលេខាប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងមានការបញ្ជាក់ចុះហត្ថលេខា និងបោះត្រាគណៈកម្មាធិការគណបក្សថ្នាក់របស់ខ្លួន ផ្ញើជូនគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនត្រូវបានផ្ទេរភារកិច្ចទៅបម្រើការងារនៅទីនោះ ។

* ទន្ទឹមនឹងការឧទ្ទេសនាមផ្ទេរសមាជិកគណបក្ស ដែលជាមន្ត្រីដឹកនាំរបស់គណបក្ស ត្រូវចម្លងជូនភ្ជាប់ជាមួយនូវជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានចុះហត្ថលេខា និងបោះត្រាបញ្ជាក់ដោយគណៈកម្មាធិការគណបក្ស ឬគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ។

**គណបក្សប្រជាជនកម្ពុជា**

គណៈកម្មាធិការកណ្តាល

លេខ: ០០១/០១២៥/សណ.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃសៅរ៍ ៤រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# ការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

**យោង** :
- ស្មារតីនៃមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស ពីថ្ងៃទី ៣០ ខែមករា ដល់ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៥ អំពីយុទ្ធសាស្ត្រ "ផ្អែកលើអំពើល្អរបស់មន្ត្រីគណបក្ស គុណភាព និងបរិមាណសមាជិកគណបក្ស ដើម្បីឈ្នះឆ្នោត"
- សេចក្តីណែនាំលេខ ២០/១៧ សណ.គក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីវិធានការមួយចំនួនសម្រាប់អនុវត្តយុទ្ធសាស្ត្រ "សមាជិកគណបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក"
- សេក្តីណែនាំលេខ ០០៩/១១២០ សណ.គក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្តិពីការធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជា
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលនាថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២៥

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល**ណែនាំអំពីវិធានការមួយចំនួនសម្រាប់អនុវត្តការងារគ្រប់គ្រងបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា ដូចខាងក្រោម៖

១- បញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជានៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ទាំងអស់ និងនៅក្រៅប្រទេស ត្រូវបានបញ្ចូលមកក្នុងប្រព័ន្ធ Server រៀបចំជាបញ្ជីសមាជិកគណបក្សតែមួយគ្រប់គ្រងដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលរួចហើយ ។ បញ្ជីសមាជិកគណបក្សនៅក្នុងប្រព័ន្ធ Server ត្រូវបានផ្ទៀងផ្ទាត់ទិន្នន័យជាមួយបញ្ជីបោះឆ្នោត ដើម្បីធានាថាសមាជិកគណបក្សមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មានទិន្នន័យត្រឹមត្រូវដូចក្នុងអត្តសញ្ញាណប័ណ្ណ និងក្នុងបញ្ជីបោះឆ្នោត គ្មានឈ្មោះស្ទួន ដែលបានបង្កលក្ខណសម្បត្តិងាយស្រួល និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងកសាងពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្សឆ្ពោះទៅកាន់ការបោះឆ្នោត ។

បញ្ជីមន្ត្រីគណបក្សនៅគ្រប់ថ្នាក់ ក៏ត្រូវបានបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ Server សម្រេចបានជាមូលដ្ឋានរួចហើយ ដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីគណបក្សតាមគោលការណ៍ណែនាំឯកភាព មានទិន្នន័យច្បាស់លាស់ ពិតប្រាកដ និងចងក្រងរក្សាទុកឯកសារពាក់ព័ន្ធមន្ត្រីគណបក្ស ។

២- ទិន្នន័យសមាជិកគណបក្សដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ Server ត្រូវមានលក្ខណសម្បត្តិស្របតាមមាត្រាទី ៥ ជំពូក III នៃលក្ខន្តិកៈគណបក្ស និងត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៣- ត្រូវបញ្ចូលទិន្នន័យមន្ត្រីគណបក្សទាំងអស់ទៅក្នុងប្រព័ន្ធ Server ដើម្បីគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា និងប្រើប្រាស់សម្រាប់ការពិនិត្យវាយតម្លៃរៀបចំមន្ត្រី និងការរៀបចំបញ្ជីបេក្ខជនរបស់គណបក្ស ។

៤- ត្រូវបន្តជំរុញការបោះពុម្ពប័ណ្ណសមាជិកគណបក្ស តាមទិន្នន័យចេញពីបញ្ជីសមាជិកគណបក្សក្នុងប្រព័ន្ធ Server ចែកជូនផ្ទាល់ដល់សមាជិកគណបក្សទាំងអស់នៅមូលដ្ឋាន ដើម្បីត្រួតពិនិត្យវត្តមានសមាជិកគណបក្សជាអ្នកគាំទ្រគណបក្សពិតប្រាកដ និងបន្តកសាងពង្រឹងពង្រីកសមាជិក និងកម្លាំងគាំទ្រគណបក្ស ឆ្ពោះទៅកាន់ការបោះឆ្នោតនាពេលខាងមុខ ។ បញ្ចប់ការចេញប័ណ្ណសមាជិកគណបក្សដោយគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

៥- ត្រូវបន្តរៀបចំការផ្តល់ប័ណ្ណមន្ត្រីគណបក្សតាមទិន្នន័យចេញពីប្រព័ន្ធ Server ដើម្បីត្រួតពិនិត្យពង្រឹងការគ្រប់គ្រងមន្ត្រីគណបក្ស ជាពិសេសចំពោះមន្ត្រីនយោបាយ និងមន្ត្រីគ្រប់គ្រងដោយថ្នាក់កណ្តាល ។

ខុទ្ទកាល័យ និងគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្សដែលពាក់ព័ន្ធ គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មានភារកិច្ចចាត់តាំងអនុវត្តសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព ។

**ជ.គណៈអចិន្ត្រៃយ៍**
**ប្រធាន**

**ហ៊ុន សែន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល
**គណៈចាត់តាំង**
លេខ: ២២៨/ចត.គក
/២២

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២២

# ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំទទួលបន្ទុកការងារចាត់តាំងគណបក្សក្រសួង ស្ថាប័ន**
- **ឯកឧត្តម លោកជំទាវ ប្រធានគណៈប្រចាំការ និងប្រធានគណៈចាត់តាំងគណបក្សរាជធានី ខេត្ត**
- **ក្រុម IT បញ្ជីសមាជិកគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការបែងចែកភារកិច្ច ពិនិត្យ កែតម្រូវទិន្នន័យក្នុងបញ្ជីសមាជិកគណបក្ស

តាមកម្មវត្ថុខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ណែនាំបន្ថែមអំពីការងារជាក់ស្តែង ២ ដែលបានកើតឡើងនៅក្នុងដំណើរការពិនិត្យ កែតម្រូវទិន្នន័យក្នុងបញ្ជីសមាជិកគណបក្សដូចខាងក្រោម :

I. **អំពីភារកិច្ចបញ្ចូលទិន្នន័យ និងពិនិត្យកែតម្រូវទិន្នន័យសមាជិកគណបក្ស**

១. អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់មានភារកិច្ចបញ្ចូលទិន្នន័យសមាជិកគណបក្ស ដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួនទៅក្នុងបញ្ជីសមាជិកគណបក្ស ។ ដើម្បីបម្រើដល់ការងារបោះឆ្នោត ទិន្នន័យសមាជិកគណបក្សទាំងអស់ក៏ត្រូវបានបញ្ចូលទៅក្នុងបញ្ជីសមាជិកគណបក្សនៅតាមឃុំ សង្កាត់ ដែលសាមីខ្លួនមានឈ្មោះបោះឆ្នោត ដោយមានកំណត់សម្គាល់ជាសមាជិកគណបក្សមកពីក្រសួង ស្ថាប័ន មកពីរាជធានី ខេត្ត មកពីក្រុង ស្រុក ខណ្ឌ (ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំ សង្កាត់) ។

២. ការបែងចែកភារកិច្ចបញ្ចូលទិន្នន័យសមាជិកគណបក្សនៅតាមបណ្តាថ្នាក់រួមមាន :

- ក្រុម IT បញ្ជីសមាជិកគណបក្សក្រសួង ស្ថាប័ន បញ្ចូលទិន្នន័យសមាជិកគណបក្សទាំងអស់នៃក្រសួង ស្ថាប័ន របស់ខ្លួន ។
- ក្រុម IT គណៈចាត់តាំងគណៈកម្មាធិការកណ្តាល ស្រង់ទិន្នន័យសមាជិកគណបក្សនៃក្រសួង ស្ថាប័ន បញ្ចូលទៅក្នុងបញ្ជីសមាជិកគណបក្សនៅតាមឃុំ សង្កាត់ ដែលសាមីខ្លួនមានឈ្មោះបោះឆ្នោត ដោយមានកំណត់សម្គាល់ជាសមាជិកគណបក្សមកពី ក្រសួង ស្ថាប័ន និងចម្លងបញ្ជីឈ្មោះនេះជូនដំណឹងដល់ក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត (ឬអាចស្នើសុំក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត បញ្ចូលទិន្នន័យបញ្ជីឈ្មោះនេះទៅតាមឃុំ សង្កាត់ដូចខាងលើនេះ) ។
- ក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត បញ្ចូលទិន្នន័យសមាជិកគណបក្សនៃគណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាគណបក្សចំណុះផ្ទាល់គណបក្សរាជធានី ខេត្ត ដោយមានកំណត់សម្គាល់ជាសមាជិកគណបក្សមកពីរាជធានី ខេត្ត បញ្ចូលទិន្នន័យសមាជិកគណបក្សជាតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភាដែលត្រូវបានចូលរួមជីវភាពគណបក្សជាមួយរាជធានី ខេត្ត និងបានបញ្ចូលទិន្នន័យសមាជិកគណបក្សពីក្រសួង ស្ថាប័នមួយចំនួនដែលជាសមាជិកក្រុមការងារគណបក្សចុះមូលដ្ឋាន ។

- ក្រុម IT បញ្ជីសមាជិកគណបក្សក្រុង ស្រុក ខណ្ឌ បញ្ចូលទិន្នន័យសមាជិកគណបក្សនៃគណៈកម្មាធិការគណបក្សមូលដ្ឋាន និងសាខាគណបក្សចំណុះគណបក្ស ក្រុង ស្រុក ខណ្ឌ ដោយមានកំណត់សម្គាល់ជាសមាជិកគណបក្សមកពីក្រុង ស្រុក ខណ្ឌ ។

- ក្រុម IT បញ្ជីសមាជិកគណបក្សឃុំ សង្កាត់ បញ្ចូលទិន្នន័យសមាជិកគណបក្សទាំងអស់ស្ថិតក្នុងអង្គការចាត់តាំងមូលដ្ឋានឃុំ សង្កាត់ របស់ខ្លួន ។

៣. យោងតាមការបែងចែកភារកិច្ច បញ្ចូលទិន្នន័យសមាជិកគណបក្សដូចខាងលើ ការពិនិត្យ កែតម្រូវទិន្នន័យសមាជិកគណបក្សតាមលំដាប់ថ្នាក់ ត្រូវបានកំណត់សិទ្ធិដូចខាងក្រោម :

- ក្រុម IT គណៈចាត់តាំងគណៈកម្មាធិការកណ្តាល ពិនិត្យ កែតម្រូវទិន្នន័យសមាជិកគណបក្សដែលមានកំណត់សម្គាល់មកពីក្រសួង ស្ថាប័ន (រួមទាំងទិន្នន័យសមាជិកគណបក្សមកពីក្រសួង ស្ថាប័ន ដែលបានបញ្ចូលដោយក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត) ។

- ក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត ពិនិត្យ កែតម្រូវទិន្នន័យសមាជិកគណបក្ស ដែលមានកំណត់សម្គាល់មកពីរាជធានី ខេត្ត និងមកពីក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចំណុះរបស់ខ្លួន ។

- ក្រុម IT បញ្ជីសមាជិកគណបក្សក្រុង ស្រុក ខណ្ឌ ពិនិត្យ កែតម្រូវទិន្នន័យសមាជិកគណបក្សដែលមានកំណត់សម្គាល់មកពីក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ចំណុះរបស់ខ្លួន ។

- ក្រុម IT បញ្ជីសមាជិកគណបក្ស ឃុំ សង្កាត់ មានសិទ្ធិកែតម្រូវតែទិន្នន័យសមាជិកគណបក្សនៅក្នុងឃុំ សង្កាត់ ប៉ុណ្ណោះ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន មិនត្រូវកែ ឬលុបឈ្មោះសមាជិកគណបក្សដែលមានកំណត់សម្គាល់មកពីក្រសួង ស្ថាប័ន មកពីរាជធានី ខេត្ត មកពីក្រុង ស្រុក ខណ្ឌ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ឃុំ សង្កាត់ នោះទេ ។

- ក្រុម IT បញ្ជីសមាជិកគណបក្សរាជធានី ខេត្ត ត្រូវជូនដំណឹង និងធ្វើការណែនាំការងារជាក់ស្តែងដល់ក្រុម IT បញ្ជីសមាជិកគណបក្សថ្នាក់ក្រោមចំណុះរបស់ខ្លួនអនុវត្តឲ្យបានល្អនូវការកំណត់បែងចែកភារកិច្ចបញ្ចូលទិន្នន័យ និងពិនិត្យកែតម្រូវទិន្នន័យសមាជិកគណបក្សដូចខាងលើនេះ ។

## II. អំពីការពិនិត្យលុបឈ្មោះស្ទួនក្នុងបញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័ន

១. យោងតាមគោលការណ៍កំណត់នៃលក្ខន្តិកៈគណបក្ស សមាជិកគណបក្សម្នាក់ៗ ត្រូវចូលរួមជីវភាពគណបក្សនៅក្នុងសាខាគណបក្សមួយ ដូច្នេះត្រូវមានឈ្មោះក្នុងបញ្ជីសមាជិកគណបក្សតែមួយប៉ុណ្ណោះ ។ លើការជាក់ស្តែង សមាជិកគណបក្សមួយចំនួន មានក្របខណ្ឌ និងបំពេញការងារនៅច្រើនកន្លែង ឬជាសមាជិកក្រុមការងារគណបក្ស សមាជិកគណៈកម្មការនានាច្រើន ដែលនៅកន្លែងខ្លះមានការគ្រប់គ្រងមិនច្បាស់លាស់បានចុះឈ្មោះក្នុងបញ្ជីសមាជិកគណបក្សច្រើនកន្លែង ។

២. ក្រុម IT គណៈចាត់តាំងគណៈកម្មាធិការកណ្តាល បានពិនិត្យបញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័ន ដែលបានផ្ញើមក រកឃើញសមាជិកគណបក្សមួយចំនួន មានឈ្មោះស្ទួន ហើយបានផ្ញើបញ្ជីឈ្មោះស្ទួននេះជូនក្រុម IT បញ្ជីសមាជិកគណបក្សក្រសួង ស្ថាប័ន ដើម្បីពិនិត្យលុបឈ្មោះស្ទួន ដោយរក្សាទុកឈ្មោះតែមួយក្នុងបញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័ន មុនពេលដាក់បញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ Server ។

៣. ចំពោះករណីសមាជិកគណបក្សមានឈ្មោះស្ទួននៅក្នុងបញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័នច្រើន (លើសពីមួយ) ក្រុម IT បញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ

សមាជិកគណបក្សដែលមានឈ្មោះស្ទួននោះ ដើម្បីកំណត់ច្បាស់ថា សាមីខ្លួនបានចូលរួមជីវភាពគណបក្សនៅកន្លែងណា ដើម្បីស្នើក្រុម IT គណៈចាត់តាំងគណៈកម្មាធិការកណ្តាល រក្សាឈ្មោះក្នុងបញ្ជីសមាជិកគណបក្សនៅក្នុងក្រសួង ស្ថាប័នតែមួយនេះ ហើយលុបឈ្មោះពីបញ្ជីសមាជិកគណបក្សនៃក្រសួង ស្ថាប័នផ្សេងទៀត ។

* **អំពីទម្រង់បែបបទការងារ**

សុំប្រគល់ភារកិច្ចជូនក្រុម IT បញ្ជីសមាជិកគណបក្សគ្រប់ថ្នាក់ ទទួលខុសត្រូវផ្ទាល់ក្នុងការបំពេញបែបបទបញ្ជីសមាជិកគណបក្ស តាមគោលការណ៍ដូចខាងលើនេះ ក្រោយពីបានសុំយោបល់សម្រេចពីគណបក្សថ្នាក់ខ្លួន និងធ្វើតាម Group Telegram ដែលបានបង្កើតរួចហើយ សម្រាប់ទំនាក់ទំនងការងារធ្វើបញ្ជីសមាជិកគណបក្ស ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម លោកជំទាវ** រាយការណ៍ជូនប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

**គណៈចាត់តាំង**
លេខ: ២៩៦/ ចត.គក

**ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ**
**អព្យាក្រឹត និង វឌ្ឍនភាពសង្គម**

ថ្ងៃច័ន្ទ ១៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២

# ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំទទួលបន្ទុកការងារចាត់តាំងគណបក្ស ក្រសួង ស្ថាប័ន**
- **ឯកឧត្តម លោកជំទាវ ប្រធានគណៈប្រចាំការ និងប្រធានគណៈចាត់តាំងគណបក្សរាជធានី ខេត្ត**
- **ក្រុម IT បញ្ជីសមាជិកគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត**

<u>កម្មវត្ថុ</u>៖ អំពីការបញ្ចូលទិន្នន័យសមាជិកគណបក្សដែលមានឈ្មោះខុសគ្នាក្នុងបញ្ជីសមាជិកគណបក្ស និងក្នុងបញ្ជីបោះឆ្នោត

តាមកម្មវត្ថុខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល ណែនាំបន្ថែមអំពីការងារជាក់ស្ដែងក្នុងដំណើរការបញ្ចូលទិន្នន័យសមាជិកគណបក្សដូចខាងក្រោម៖

ក្នុងបញ្ជីសមាជិកគណបក្សមានមន្ត្រីបុគ្គលិកមួយចំនួនបានប្រើប្រាស់ឈ្មោះផ្លូវការដូចឈ្មោះក្នុងក្របខណ្ឌនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់ខ្លួន ទន្ទឹមនេះសាមីខ្លួនមានឈ្មោះផ្សេងទៀតក្នុងបញ្ជីបោះឆ្នោត។ ក្នុងករណីនេះ ក្នុងបញ្ជីសមាជិកគណបក្សត្រូវចុះឈ្មោះផ្លូវការរបស់សមាជិកគណបក្សនោះ និងមានបន្ថែមឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងវង់ក្រចក ហើយសរសេរបញ្ជាក់ក្នុងកំណត់សម្គាល់។

ឧទាហរណ៍ឈ្មោះក្នុងបញ្ជីសមាជិកគណបក្ស: សែន សុខ (សុខ សាន្ត)

កំណត់សម្គាល់: ឈ្មោះ សុខ សាន្ត ក្នុងបញ្ជីបោះឆ្នោត

សេចក្ដីដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តម លោកជំទាវ** ទទួលបន្ទុកការងារចាត់តាំងគណបក្សក្រសួង ស្ថាប័ន និងប្រធានគណៈចាត់តាំងគណបក្សរាជធានី ខេត្ត មេត្តាជ្រាប និងរាយការណ៍ជូនថ្នាក់ដឹកនាំគណបក្សដើម្បីចាត់ចែងអនុវត្តតាមការគួរ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល
**គណៈចាត់តាំង**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ថ្ងៃចន្ទ ៧ រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២៥

# ជំនួយស្មារតី

## អំពីការរៀបចំជីវភាពបក្សរបស់សមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រ

**យោង**:-ស្មារតីសម្រេចនៃសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៧

-សេចក្តីណែនាំលេខ ០០១/១១២៥ សណ.គក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៥ ស្តីពីការងារគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស និងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ស្នើគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត អនុវត្តការងារគ្រប់គ្រងជីវភាពបក្ស និងបញ្ជីសមាជិកគណបក្ស ដែលជាសមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រ តាមគោលការណ៍ដូចខាងក្រោមៈ

១-សមាជិកគណបក្ស ដែលជាសមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រ ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងផ្ទាល់របស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។

២-សមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រ ត្រូវបានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលឧទ្ទេសនាមឲ្យចូលរួមជីវភាពបក្សជាមួយគណៈកម្មាធិការគណបក្សរាជធានី ខេត្ត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួនរហូតដល់ចប់អាណត្តិ។

៣-សមាជិកគណបក្ស ដែលជាតំណាងរាស្ត្រ និងជាសមាជិករាជរដ្ឋាភិបាល ចូលរួមជីវភាពបក្សជាមួយគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន ដែលសាមីខ្លួនទទួលបន្ទុកដឹកនាំ។

៤-គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល មានភារកិច្ចសហការជាមួយគណៈកម្មាធិការគណបក្សអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងគណៈកម្មាធិការគណបក្សអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងការធ្វើបញ្ជីសមាជិកគណបក្សដែលជាសមាជិក សមាជិកាព្រឹទ្ធសភា និងតំណាងរាស្ត្រ និងការផ្ទេរជីវភាពបក្សក្រោយពេលចប់អាណត្តិ។

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

**គណៈចាត់តាំង**
លេខ: ០៤២/២៥ ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៤ខែកុម្ភៈ ឆ្នាំ ២០២៥

# គោរព និងជម្រាបជូន
## សម្ដេច ឯកឧត្ដម លោកជំទាវ ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្ដាល
## ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត

**កម្មវត្ថុ**: អំពីការគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

**យោង** :
- សេចក្ដីណែនាំលេខ ០០១/០១២៥ សណ.គក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៥
- លិខិតលេខ ០១៤/២៤ ចត.គក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៤
- លិខិតលេខ ០៩១/២៤ ចត.គក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២៤

តាមកម្មវត្ថុនិងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលសូមគោរព និងជម្រាបជូន អំពីការរៀបចំគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលត្រូវបន្តអនុវត្តដូចខាងក្រោម ៖

១- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្ដាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត បានផ្ដល់បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួនមកគណៈចាត់តាំងនៃគណៈកម្មការកណ្ដាល ដើម្បីបញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស សម្រេចបានជាមូលដ្ឋានរួចហើយ ។

២- ដើម្បីបង្កលក្ខណសម្បត្តិងាយស្រួលដល់ការគ្រប់គ្រង និងស្វែងរកទិន្នន័យនៅក្នុងប្រព័ន្ធ Server គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលបានរៀបចំគំនូសបំព្រួញនៃរចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់ ដោយមានកូដសម្គាល់អង្គការចាត់តាំងគណបក្សនីមួយៗ ដូចខាងក្រោម :

- លេខ 1 ជាកូដសម្គាល់ថ្នាក់ក្រសួង ស្ថាប័ន
- លេខ 2 ជាកូដសម្គាល់ថ្នាក់រាជធានី ខេត្ត
- លេខ 3 ជាកូដសម្គាល់ថ្នាក់ក្រុង ស្រុក ខណ្ឌ
- លេខ 4 ជាកូដសម្គាល់ថ្នាក់ឃុំ សង្កាត់
- អក្សរ A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋាន
- អក្សរ B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស
- អក្សរ C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ (ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

+ 1A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះក្រសួង ស្ថាប័ន
+ 1B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះក្រសួង ស្ថាប័ន
+ 1C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ក្រសួង ស្ថាប័ន

+ 2A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះរាជធានី ខេត្ត

+ 2B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះរាជធានី ខេត្ត

+ 2C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់រាជធានី ខេត្ត

+ 3A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះក្រុង ស្រុក ខណ្ឌ

+ 3B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះក្រុង ស្រុក ខណ្ឌ

+ 3C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ក្រុង ស្រុក ខណ្ឌ

+ 4C ជាកូដសម្គាល់សាខាគណបក្សចំណុះឃុំ សង្កាត់

+ បន្ទាប់ពីលេខ និងអក្សរជាកូដសម្គាល់ មានលេខរៀង ២ខ្ទង់ នៃអង្គការចាត់តាំងគណបក្សនីមួយៗ

*ចំពោះសាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន គឺមានលេខកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋាន និងលេខរៀង ២ខ្ទង់ នៃសាខាគណបក្សចំណុះ

*សាខាគណបក្សភូមិ ដាក់តាមឈ្មោះភូមិនីមួយៗ ដោយមិនមានកូដសម្គាល់ និងលេខរៀងទេ

*ចំពោះភូមិដែលមានសាខាគណបក្សច្រើន ដាក់ឈ្មោះជាសាខាគណបក្សទី ១, ទី ២... និងឈ្មោះភូមិ ។

៣- ស្នើគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រួតពិនិត្យផ្ទៀងផ្ទាត់និងបំពេញបន្ថែមបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួន តាមគំរូរចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សដែលមានកូដសម្គាល់ ជូនភ្ជាប់ជាមួយនេះ ផ្ញើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល ដើម្បីកែសម្រួលបំពេញបន្ថែមកម្មវិធីគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធ Server ។ ក្នុងករណី បានផ្ញើបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សមកជាជំហានៗ ឬគ្រប់អស់ហើយ សូមបញ្ជាក់ឡើងវិញអំពីចំនួនសរុបក្នុងបញ្ជីដែលបានផ្ញើមក ។

៤- ការបញ្ចូលទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស ត្រូវបន្តអនុវត្តឱ្យបានសម្រេចតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល និងការណែនាំ បណ្ដុះបណ្ដាល បំពាក់បំប៉នជំនាញដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម**សម្ដេច ឯកឧត្តម លោកជំទាវ**ប្រធានមេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលល្អ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សប្រជាជនកម្ពុជា




**ស្ថាប័ន អង្គភាពជំនួយការរបស់គណបក្ស**

១ = ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល
២ = គណៈចាត់តាំង
៣ = គណៈឃោសនាអប់រំ
៤ = គណៈកម្មាធិការត្រួតពិនិត្យ
៥ = គណៈស្រាវជ្រាវប្រវត្តិសាស្ត្រគណបក្ស
៦ = គណៈកម្មាធិការហិរញ្ញវត្ថុ
៧ = គណៈទាក់ទងបរទេស
៨ = គណៈចលនាមហាជន
៩ = យុវជនគណបក្ស
១-១ = មន្ទីរគណបក្ស រាជធានី ខេត្ត ឬ លេខាធិការដ្ឋាន
១-២ = ស្នាក់ការគណបក្សក្រុងស្រុកខណ្ឌ
១-៣ = ស្នាក់ការគណបក្ស ឃុំ សង្កាត់

__បញ្ជាក់__ ៤-៦ បោះឆ្នោតជ្រើសតាំងដោយសន្និបាតគណៈកម្មាធិការកណ្តាល ។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់




សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជិ. ............. , គណៈកម្មាធិការគណបក្សមដ. ............. , សាខាបក្សចំណុះផ្ទាល់ ............. , សាខាបក្សចំណុះគក.មដ .............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់




សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជ. ............ , គណៈកម្មាធិការគណបក្សមជ. ............ , សាខាបក្សចំណុះផ្ទាល់ ............ , សាខាបក្សចំណុះគក.មជ ............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់

## 3 គណៈកម្មាធិការគណបក្ស ក្រុង/ស្រុក/ខណ្ឌ .................

### 3B គណៈកម្មការគ្រប់គ្រងសមាជិក

- 3B01 ឈ្មោះគណៈកម្មការ
  - 3B01.01 ឈ្មោះក្រុមសមាជិក
  - 3B01.02 ឈ្មោះក្រុមសមាជិក
- 3B02 ឈ្មោះគណៈកម្មការ
  - 3B02.01 ឈ្មោះក្រុមសមាជិក
  - 3B02.02 ឈ្មោះក្រុមសមាជិក
- 3B03 ឈ្មោះគណៈកម្មការ
  - 3B03.01 ឈ្មោះក្រុមសមាជិក
  - 3B03.02 ឈ្មោះក្រុមសមាជិក

### គក.គណបក្ស ឃុំ/សង្កាត់

### 3A គណៈកម្មាធិការគណបក្សមូលដ្ឋាន

- 3A01 ឈ្មោះគក.មជ
  - 3A01.01 ឈ្មោះសាខាចំណុះគក.មជ
  - 3A01.02 ឈ្មោះសាខាចំណុះគក.មជ
- 3A02 ឈ្មោះគក.មជ
  - 3A02.01 ឈ្មោះសាខាចំណុះគក.មជ
  - 3A02.02 ឈ្មោះសាខាចំណុះគក.មជ
- 3A03 ឈ្មោះគក.មជ
  - 3A03.01 ឈ្មោះសាខាចំណុះគក.មជ
  - 3A03.02 ឈ្មោះសាខាចំណុះគក.មជ
- 3A04 ឈ្មោះគក.មជ
  - 3A04.01 ឈ្មោះសាខាចំណុះគក.មជ
  - 3A04.02 ឈ្មោះសាខាចំណុះគក.មជ

### 3C សាខាបក្សចំណុះផ្ទាល់

- 3C01 ឈ្មោះសាខា
- 3C02 ឈ្មោះសាខា
- 3C03 ឈ្មោះសាខា
- 3C04 ឈ្មោះសាខា

សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជិ. ............ , គណៈកម្មាធិការគណបក្សមជ. ............ , សាខាបក្សចំណុះផ្ទាល់ ............ , សាខាបក្សចំណុះគក.មជ ............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់

## 4 គណៈកម្មាធិការគណបក្ស ឃុំ/សង្កាត់ .................

### សាខាបក្សភូមិ

- សាខាបក្សភូមិ ...
- សាខាបក្សភូមិ ...
- សាខាបក្សទី១ ភូមិ ...
- សាខាបក្សទី២ ភូមិ ...

### 4C សាខាបក្សចំណុះ

- **4C01** ឈ្មោះសាខា
- **4C02** ឈ្មោះសាខា
- **4C03** ឈ្មោះសាខា
- **4C04** ឈ្មោះសាខា

សរុបរួម៖ សាខាបក្សភូមិ .............. សាខាបក្សចំណុះគណៈកម្មាធិការគណបក្សឃុំ/សង្កាត់ ..............។

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**

លេខ: ១៨៣/២៣ ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០២៣

# គោរព និងជម្រាបជូន

**-សម្តេច ឯកឧត្តម ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានរាជធានី ខេត្ត**
**-ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការគណបក្សរាជធានី ខេត្ត**
**-ប្រធានក្រុម IT គណបក្សរាជធានី ខេត្ត**

**កម្មវត្ថុ** : អំពីការធ្វើសៀវភៅគ្រួសារបក្សចេញពីប្រព័ន្ធ Server

**យោង** : - សេចក្តីណែនាំលេខ ០២០/១៧ លគ.គក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីវិធានការមួយចំនួន សម្រាប់អនុវត្តយុទ្ធសាស្ត្រ "សមាជិកបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក"
- សេចក្តីណែនាំលេខ ០០៩/១១២០/សណ.គក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០ ស្តីពីការធ្វើបញ្ជីសមាជិកគណបក្សប្រជាជនកម្ពុជា
- សំណូមពរការងារគ្រប់គ្រងសមាជិកគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា
- ស្មារតីអង្គប្រជុំរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលរួមជាមួយថ្នាក់ដឹកនាំទទួលបន្ទុកការងារចាត់តាំងគណបក្សនៃក្រសួង ស្ថាប័ន និងប្រធានគណៈចាត់តាំងគណបក្សរាជធានី ខេត្ត នាថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០២៣

តាមកម្មវត្ថុនិងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល សូមលើកឡើងនូវវិធានការមួយចំនួន ដើម្បីទាញយកទិន្នន័យពីបញ្ជីសមាជិកគណបក្សក្នុងប្រព័ន្ធ Server មកប្រើប្រាស់រៀបចំជាសៀវភៅគ្រួសារបក្ស បោះពុម្ពចេញពីប្រព័ន្ធ Server ដូចខាងក្រោម ៖

១- គោលការណ៍អំពីការធ្វើសៀវភៅគ្រួសារបក្ស :

- ផ្តល់ជូនសមាជិកបក្ស ដែលមានលក្ខណសម្បត្តិជាពលរដ្ឋមានឈ្មោះបោះឆ្នោតនៅក្នុងរាជធានី ខេត្តតែមួយជាមួយគ្នា ស្របតាមយុទ្ធសាស្ត្រ "សមាជិកបក្សមួយរូប គឺជាសំឡេងឆ្នោតគាំទ្រគណបក្សមួយសន្លឹក"
- ផ្តល់ជូនសមាជិកបក្ស ដែលរស់នៅជាមួយគ្នាក្នុងគ្រួសារ
- ផ្តល់ជូនសមាជិកបក្ស ដែលរស់នៅជាមួយគ្នា នៅកន្លែងធ្វើការ ឬផ្ទះជួល
- សមាជិកបក្សមួយរូប មានឈ្មោះក្នុងសៀវភៅគ្រួសារបក្សតែមួយប៉ុណ្ណោះ ។

ដោយឡែក ចំពោះមន្ត្រីជាន់ខ្ពស់របស់គណបក្ស ដែលជាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល រដ្ឋលេខាធិការ ប្រធាន អនុប្រធានស្ថាប័នជាតិ អាចជ្រើសរើសធ្វើសៀវភៅគ្រួសារបក្សនៅរាជធានី ខេត្ត ដែលសាមីខ្លួនមានឈ្មោះបោះឆ្នោត ឬនៅមូលដ្ឋានដែលមានទីលំនៅរស់នៅជាមួយគ្រួសារ ។ ក្នុងករណីនេះ គណបក្សរាជធានី ខេត្ត ត្រូវជូនដំណឹងមកក្រុម IT គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីទាញយកទិន្នន័យមន្ត្រីជាន់ខ្ពស់របស់គណបក្ស បញ្ចូលទៅក្នុងសៀវភៅគ្រួសារបក្សដែលមានសមាជិកបក្សមកពីរាជធានី ខេត្តខុសគ្នា និងមានកំណត់សម្គាល់ជាសមាជិកបក្សរាជធានី ខេត្ត ផ្សេង ។

សមាជិកបក្សទូទៅផ្សេងទៀត ពេលបែកចេញពីគ្រួសារទៅធ្វើការនិងបានចុះឈ្មោះបោះឆ្នោតនៅរាជធានី ខេត្តផ្សេងក្រៅពីមូលដ្ឋាននៃទីលំនៅគ្រួសាររបស់ខ្លួន ទោះបីនៅលីវមិនទាន់មានគ្រួសារ ក៏ត្រូវផ្ទេរឈ្មោះចេញពីសៀវភៅគ្រួសារបក្សនោះ ហើយអាចចុះឈ្មោះក្នុងសៀវភៅគ្រួសារបក្សនៅផ្ទះដែលសាមីខ្លួនស្នាក់នៅ ឬចុះសៀវភៅគ្រួសារបក្សសម្រាប់ក្រុមសមាជិកបក្សដែលរស់នៅជាមួយគ្នានៅកន្លែងធ្វើការ ឬផ្ទះជួល តាមអាសយដ្ឋាន

ដែលសាមីខ្លួនបានប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោត ។ ក្នុងកំណត់សម្គាល់សៀវភៅគ្រួសារបក្ស អាចសរសេរបញ្ជាក់ថាមានសមាជិកគ្រួសារ ជាសមាជិកបក្សនៅរាជធានី ខេត្ត ផ្សេង ។

២- ទម្រង់និងខ្លឹមសារនៃសៀវភៅគ្រួសារបក្ស ត្រូវបានរៀបចំកែលម្អលើមូលដ្ឋាននៃគំរូសៀវភៅគ្រួសារបក្សឆ្នាំ ២០១៧ ដែលអាចបោះពុម្ពលើក្រដាសទំហំ A4 មួយសន្លឹក។

- ខ្លឹមសារខាងក្រៅរួមមាន : គោលការណ៍អំពីការធ្វើសៀវភៅគ្រួសារបក្ស ភារកិច្ចរបស់សមាជិកបក្ស ភារកិច្ចរបស់មេគ្រួសារបក្ស ឈ្មោះនិងរូបសញ្ញាគណបក្សប្រជាជនកម្ពុជា ឈ្មោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ និងលេខសៀវភៅគ្រួសារបក្ស ។

- ខ្លឹមសារខាងក្នុងរួមមាន : លេខសៀវភៅគ្រួសារបក្ស និងថ្ងៃបោះពុម្ព ទិន្នន័យសមាជិកបក្សដែលមានរូបថត ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ថ្ងៃខែឆ្នាំចូលបក្ស លេខប័ណ្ណសមាជិកបក្ស អត្តលេខបោះឆ្នោត លេខអត្តសញ្ញាណប័ណ្ណ និងកំណត់សម្គាល់ផ្សេងៗសម្រាប់សមាជិកបក្សម្នាក់ៗ (សរុបដល់ ១២ នាក់) កំណត់សម្គាល់ផ្សេងៗសម្រាប់សៀវភៅគ្រួសារបក្ស និង QR Code ។

៣- ក្រុម IT គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល និងក្រុម IT គណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានគណនី Data Entries មានភារកិច្ចសហការជាមួយអង្គការចាត់តាំងគណបក្សនៅមូលដ្ឋាន ស្វែងរកទិន្នន័យក្នុងប្រព័ន្ធ Server ដើម្បីទាញបញ្ចូលមកបង្កើតជាសៀវភៅគ្រួសារបក្ស និងអាចបោះពុម្ពបញ្ជីរួមសៀវភៅគ្រួសារបក្សចេញពីប្រព័ន្ធ Server បាន ។

៤- លេខសៀវភៅគ្រួសារបក្ស រួមមានលេខកូដ ៧ ខ្ទង់ ដូចលេខកូដរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលកំណត់ដោយ គ.ជ.ប និងលេខរៀងសៀវភៅគ្រួសារបក្សតាមភូមិចំនួន ៤ខ្ទង់ ។ ឧទាហរណ៍ : សៀវភៅគ្រួសារបក្សក្នុងសង្កាត់ចតុមុខ រាជធានីភ្នំពេញ លេខ 1202-019-0001 ។

៥- ការបោះពុម្ពសៀវភៅគ្រួសារបក្ស គឺជាបន្ទុកទទួលខុសត្រូវ និងចំណាយ របស់គណបក្សរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ យោងតាមសំណើរបស់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលនឹងជួយសម្រួលការបោះពុម្ពសៀវភៅគ្រួសារបក្សចេញពីប្រព័ន្ធ Server ដែលមានតម្លៃផលិតត្រឹម ២.០០០រៀល ដោយមិនគិតពីកម្លាំងពលកម្ម ហើយក៏សូមអំពាវនាវដល់គណៈកម្មាធិការគណបក្សដែលមានសំណូមពរបោះពុម្ព សូមមេត្តាផ្តល់ការជួយឧបត្ថម្ភដល់មន្ត្រីបុគ្គលិកដែលត្រូវចូលរួមធ្វើការងារនេះតាមលទ្ធភាពជាក់ស្តែង ។

៦- ទិន្នន័យបញ្ជីសមាជិកបក្សត្រូវធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ ។ ដោយឡែក ការធ្វើបច្ចុប្បន្នភាពសៀវភៅគ្រួសារបក្ស គួរត្រួតពិនិត្យធ្វើបច្ចុប្បន្នភាពនៅឆ្នាំមុនពេលមានការបោះឆ្នោតសកល ឬនៅពេលមានសំណូមពរជាក់ស្តែង ។ ការចុះថ្ងៃបោះពុម្ពសៀវភៅគ្រួសារបក្សដើម្បីបញ្ជាក់ពីកាលបរិច្ឆេទនៃការធ្វើបច្ចុប្បន្នភាពសៀវភៅគ្រួសារបក្ស ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**សម្តេច ឯកឧត្តម លោកជំទាវ** ប្រធាន មេត្តាជ្រាប និងចាត់ចែងដើម្បីចូលរួមសហការអនុវត្តឲ្យសម្រេចបានលទ្ធផលល្អ ស្របតាមគោលការណ៍ណែនាំរបស់គណបក្ស ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត!

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល
**គណៈចាត់តាំង**
លេខៈ ១៦១/២៥ ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃពុធ ១៣រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៣ខែកក្កដា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# វិធានការពង្រឹងសុវត្ថិភាពនៃដំណើរការ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស

**យោង** : - ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២៥

- ចំណារឯកភាពរបស់**សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានគណបក្ស ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០២៥
- សេចក្តីជូនដំណឹងលេខ ១៦៥៥ បទ. ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២៥ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្តីពីការប្រុងប្រយ័ត្នចំពោះកំណើននៃការវាយប្រហារសាយប័រ
- សេចក្តីណែនាំលេខ ១២០/២២ ចត.គក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២២ អំពីការផ្តល់គណនីសម្រាប់ចូលក្នុងកម្មវិធីនៃប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកគណបក្ស

ក្នុងសភាពការណ៍ថ្មីនាពេលបច្ចុប្បន្ន មានការកើនឡើងនូវការវាយប្រហារសាយប័រលើប្រព័ន្ធ Server របស់ក្រសួង ស្ថាប័ន មួយចំនួន និងរបស់គណបក្សយើងផងដែរ ។ ដើម្បីពង្រឹងសន្តិសុខសុវត្ថិភាពនៃប្រព័ន្ធ Server ទប់ស្កាត់ការវាយប្រហារប៉ុនប៉ងធ្វើឱ្យប៉ះពាល់ខូចខាតដល់ដំណើរការនៃប្រព័ន្ធ ការលួចចូលគ្រប់គ្រងគណនីរបស់អ្នកប្រើប្រាស់ប្រព័ន្ធ ការលួច ឬបំផ្លាញទិន្នន័យក្នុងប្រពន្ធ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលណែនាំពង្រឹងវិធានការមួយចំនួននៃដំណើរការប្រព័ន្ធ Server គ្រប់គ្រងទិន្នន័យរបស់គណៈចាត់តាំងគណៈកម្មាធិការកណ្តាល ដូចខាងក្រោម ៖

១- រៀបចំឡើងវិញការផ្តល់គណនីសម្រាប់មន្ត្រីគណបក្សចូលធ្វើការក្នុងប្រព័ន្ធ រួមមាន:

- គណនី Read Only ចំនួន ២ និងគណនី Data Entry ចំនួន ២ សម្រាប់ក្រសួង ស្ថាប័ននីមួយៗ
- គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់គណបក្សមូលដ្ឋាននីមួយៗចំណុះក្រសួង ស្ថាប័ន
- គណនី Read Only ចំនួន ៣ និងគណនី Data Entry ចំនួន ៣ សម្រាប់រាជធានី ខេត្តនីមួយៗ
- គណនី Read Only ចំនួន ២ និងគណនី Data Entry ចំនួន ២ សម្រាប់ក្រុង ស្រុក ខណ្ឌនីមួយៗ
- គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់ឃុំ សង្កាត់នីមួយៗ

២- ផ្តល់សិទ្ធិជូនអ្នកប្រើប្រាស់គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ (ក្នុងចំណោមអ្នកប្រើប្រាស់គណនីដូចខាងលើនេះ) សម្រាប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ចូលធ្វើការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ។

៣- ផ្ដល់សិទ្ធិជូនអ្នកប្រើប្រាស់គណនី Read Only ចំនួន ១ និងគណនី Data Entry ចំនួន ១ សម្រាប់រាជធានី ខេត្តនីមួយៗ ចូលធ្វើការគ្រប់គ្រងបញ្ជីសមាជិកគណបក្សករណីពិសេសដោយឡែករបស់រាជធានី ខេត្ត ។

៤- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្ដាល គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ធ្វើសំណើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល សុំផ្ដល់គណនីតាមចំនួនកំណត់ដូចខាងលើនេះ តាមទម្រង់បែបបទដូចមានចែងក្នុងសេចក្ដីណែនាំលេខ ១២០/២២ ចត.គក ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២២ ។

៥- ប្រើប្រាស់មុខងារសុវត្ថិភាពចាក់សោពីរជាន់ (Two-Factor Authentication) សម្រាប់អ្នកប្រើប្រាស់គណនី Log In ចូលធ្វើការក្នុងប្រព័ន្ធ Server ដោយប្រើ E-mail ផ្ទាល់ខ្លួន ។ ទន្ទឹមនេះ ណែនាំជំរុញអ្នកប្រើប្រាស់គណនីអំពីការប្រើប្រាស់ CamDigiKey-Apps នៅពេលខាងមុខ ។

៦- គណនីដែលមិនបានប្រើប្រាស់ចូលធ្វើការក្នុងប្រព័ន្ធ Server រយៈពេល ៣០ ថ្ងៃ នឹងត្រូវបិទដោយស្វ័យប្រវត្តិ ។ ក្នុងករណីនេះ អ្នកប្រើប្រាស់គណនីត្រូវធ្វើសំណើសុំក្រុម IT គណៈចាត់តាំងគណៈកម្មាធិការកណ្ដាល បើកគណនីឡើងវិញ ទើបអាចបន្តប្រើប្រាស់ចូលធ្វើការក្នុងប្រព័ន្ធ Server បាន ។

៧- ក្រុម IT គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលរៀបចំកម្មវិធីជាតារាង Excel សម្រាប់មន្ត្រី IT គណបក្សគ្រប់ថ្នាក់បញ្ចូល និងបញ្ជូនទិន្នន័យមកឱ្យអ្នកប្រើប្រាស់គណនី Data Entry ពិនិត្យផ្ទៀងផ្ទាត់ និងបញ្ចូលក្នុងប្រព័ន្ធ Server ។ ត្រូវរៀបចំកម្មវិធីជាតារាង Excel ចំនួន ២ រួមមាន:

- បញ្ជីរាយនាមសមាជិកគណបក្ស រៀបចំតាមគំរូឯកភាពរបស់គណបក្ស ភ្ជាប់ជាមួយទិន្នន័យដែលត្រូវចម្លងបញ្ចូលមកពីបញ្ជីបោះឆ្នោត
- បញ្ជីរាយនាមមន្ត្រីគណបក្ស រៀបចំលើមូលដ្ឋាននៃតារាង Excel បញ្ជីរាយនាមសមាជិកគណបក្ស និងបំពេញបន្ថែមទិន្នន័យសម្រាប់ការងារគ្រប់គ្រងមន្ត្រីគណបក្ស ។

៨- បន្តបំពាក់បំប៉នដល់មន្ត្រី IT គណបក្សគ្រប់ថ្នាក់ធ្វើការបញ្ចូល និងបញ្ជូនទិន្នន័យតាមតារាង Excel ជំនួសការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ Server ដើម្បីឈានទៅកាត់បន្ថយចំនួនអ្នកប្រើប្រាស់គណនី Data Entry ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម**សម្ដេច ឯកឧត្តម លោកជំទាវ** ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្ដាល ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មេត្តាជ្រាប និងចូលរួមសហការចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព ស្របតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**

លេខ:០១៤/២៤ ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃសុក្រ ៩កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៤

# គោរព និងជម្រាបជូន

## សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត

**កម្មវត្ថុ** : អំពីដំណើរការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា និងផលិតប័ណ្ណសម្គាល់មន្ត្រីគណបក្ស និងប័ណ្ណសម្គាល់សមាជិកគណបក្សមាន QR Code

**យោង** : - ចំណារឯកភាពជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** អនុប្រធានគណបក្ស និងជាប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២៣ លើសំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលលេខ ២៥០/២៣ ចត.គក ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ ២០២៣ អំពីការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា និងការរៀបចំ QR Code

- ស្មារតីអង្គប្រជុំតាមប្រព័ន្ធ ZOOM ជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញការងារចាត់តាំងនៃគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត នាថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៤ ។

តាមកម្មវត្ថុ និងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលសូមគោរព និងជម្រាបជូនអំពីដំណើរការ ការងារដូចខាងក្រោម ៖

### I. អំពីដំណើរការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា

១- បន្ទាប់ពីជោគជ័យក្នុងការធ្វើបញ្ជីរាយនាមសមាជិកគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បានរៀបចំដំណើការប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងរបស់ថ្នាក់កណ្តាល តាមប្រព័ន្ធព័ត៌មានវិទ្យារួចហើយ ។

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បន្តរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្សនៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលនឹងដំណើរការនៅពេលខាងមុខនេះ ដើម្បីបង្កលក្ខណសម្បត្តិងាយស្រួលថែមទៀតដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការគ្រប់គ្រងមន្ត្រីគណបក្សរបស់ខ្លួនតាមប្រព័ន្ធព័ត៌មានវិទ្យាឯកភាពតាមគំរូតារាងផ្សេងៗដែលបានណែនាំអនុវត្តកន្លងមក ។

២- ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ត្រូវបានរៀបចំឲ្យដំណើរការនៅក្នុងប្រព័ន្ធ Server គ្រប់គ្រងដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល រួមជាមួយប្រព័ន្ធគ្រប់គ្រងបញ្ជីសមាជិកគណបក្សដែលត្រូវបានបង្ហោះជាវេបសាយឈ្មោះ www.cppco.org.kh ។

ប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីគណបក្ស ត្រូវបានដាក់ឲ្យប្រើប្រាស់លើ MENU ឈ្មោះថា "ប្រព័ន្ធគ្រប់គ្រងការងារចាត់តាំង" ។

៣- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បានផ្តល់គណនីជូនថ្នាក់ដឹកនាំគណបក្ស និងមន្ត្រីជំនាញនៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រួចហើយដើម្បីចូលពិនិត្យមើល និងធ្វើការក្នុងប្រព័ន្ធ Server រួមមាន ៖

- គណនី Read Only ចំនួន ១០ និងគណនី Data Entry ចំនួន ១០ សម្រាប់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត នីមួយៗ
- គណនី Read Only ចំនួន ៥ និងគណនី Data Entry ចំនួន ៥ សម្រាប់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីមួយៗ ។

ថ្នាក់ដឹកនាំគណបក្ស និងមន្ត្រីជំនាញដែលមានគណនីដូចខាងលើ និងបានចូលរួមធ្វើការក្នុងប្រព័ន្ធគ្រប់គ្រងបញ្ជីសមាជិកគណបក្សកន្លងមក មានភារកិច្ចបន្តធ្វើការងារក្នុង "ប្រព័ន្ធគ្រប់គ្រងការងារចាត់តាំង" នេះ ។ ក្នុងករណីដែលមានការផ្លាស់ប្តូរ សូមធ្វើសំណើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីរៀបចំ Reset Password ឬផ្តល់ជូនគណនីថ្មី ។

៤- ការបញ្ចូលទិន្នន័យមន្ត្រីគណបក្សក្នុងប្រព័ន្ធ Server រួមមានសមាសភាព ៖

- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងប្រធានក្រុមសមាជិក
- គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងគណៈកម្មាធិការគណបក្សមូលដ្ឋាន គណៈកម្មាធិការសាខាបក្ស (ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសាខា)
- ប្រធាន (អនុប្រធាន) អនុសាខា ប្រធាន(អនុប្រធាន) ក្រុមបក្ស មេគ្រួសារបក្ស
- សមាជិកគណៈកម្មាធិការកណ្តាលនៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត
- ស្ថាប័នជំនួយការគណបក្សគ្រប់ថ្នាក់ ដូចជា ប្រធាន អនុប្រធាន សមាជិក និងជំនួយការនៃលេខាធិការដ្ឋាន ឬក្រុមជំនួយការគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ឬមន្ទីរគណបក្ស ឬស្នាក់ការគណបក្ស គណៈចាត់តាំង គណៈឃោសនាអប់រំ គណៈកម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការហិរញ្ញវត្ថុ គណៈចលនាមហាជន ក្រុមការងារយុវជនគណបក្ស
- ប្រធាន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- អភិបាល និងអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- មេឃុំ ចៅសង្កាត់ ជំទប់-ចៅសង្កាត់រងទី ១ និងទី ២
- ក្រុមការងារគណបក្សចុះមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ (ដោយមានបន្ថែមតួនាទីក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន)

៥- ទិន្នន័យមន្ត្រីគណបក្សម្នាក់ៗ ត្រូវវាយបញ្ចូលទៅក្នុងតារាងបញ្ចូលទិន្នន័យមន្ត្រីគណបក្សតាមក្រសួង ស្ថាប័ន ឬតារាងបញ្ចូលទិន្នន័យមន្ត្រីគណបក្ស តាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ។ ទិន្នន័យដែលបានវាយបញ្ចូលត្រូវបានបង្ហាញឲ្យឃើញ និងអាចទាញយកចេញពីប្រព័ន្ធ Server ជា៖

- បញ្ជីរាយនាមសមាជិកគណៈកម្មាធិការកណ្តាលនៅក្នុងក្រសួង ស្ថាប័ន រាជធានី ខេត្ត
- បញ្ជីរាយនាមគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស
- បញ្ជីរាយនាមសមាជិកគណៈកម្មាធិការគណបក្ស

- បញ្ជីរាយនាមគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- បញ្ជីរាយនាមគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស
- បញ្ជីរាយនាមមន្ត្រីនៃលេខាធិការដ្ឋាន ឬក្រុមជំនួយការ ឬមន្ទីរគណបក្ស ឬស្នាក់ការគណបក្ស
- បញ្ជីរាយនាមមន្ត្រីនៃគណៈជំនាញនានារបស់គណបក្ស
- បញ្ជីរាយនាមក្រុមការងារយុវជនគណបក្ស
- បញ្ជីរាយនាមគណៈកម្មាធិការសាខាគណបក្ស ឬប្រធាន អនុប្រធានសាខាគណបក្ស
- បញ្ជីរាយនាមក្រុមប្រឹក្សា
- បញ្ជីរាយនាមគណៈអភិបាល
- បញ្ជីរាយនាមមេឃុំ-ចៅសង្កាត់ និងជំទប់-ចៅសង្កាត់រង
- បញ្ជីរាយនាមមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ
- បញ្ជីរាយនាមក្រុមការងារគណបក្សចុះមូលដ្ឋាន
- ជីវប្រវត្តិ និងសេចក្តីសម្រេច និងឯកសារពាក់ព័ន្ធរបស់មន្ត្រីគណបក្សម្នាក់ៗ
- តារាងស្ថិតិមន្ត្រី និងអង្គការចាត់តាំងគណបក្សតាមលំដាប់ថ្នាក់ដែលមានការគណនាបូកសរុប វិភាគតាមកម្រិតអាយុ ភេទ រហូតដល់អនុសាខា ក្រុមបក្ស គ្រួសារបក្ស ។

៦- "ប្រព័ន្ធគ្រប់គ្រងការងារចាត់តាំង" និងដាក់ឲ្យដំណើរការនៅថ្ងៃទី ១៤ ខែកុម្ភៈ និងខិតខំសម្រេចបញ្ចប់ការបញ្ចូលទិន្នន័យមន្ត្រីគណបក្សត្រឹមដំណាច់ឆ្នាំ ២០២៤ ដើម្បីអាចប្រើប្រាស់ទិន្នន័យចេញពីប្រព័ន្ធ Server សម្រាប់ធ្វើរបាយការណ៍នៅខែមករា ឆ្នាំ ២០២៥ ។

៧- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល រៀបចំបើកវគ្គបណ្តុះបណ្តាលអំពីការងារបញ្ចូលទិន្នន័យមន្ត្រីគណបក្សនៅវិមាន ៧មករា រយៈពេល ១ព្រឹក(ថ្ងៃទី ១៥កុម្ភៈ) ជូនមន្ត្រីជំនាញ IT ២នាក់មកពីក្រសួងស្ថាប័ននីមួយៗ និង ១ព្រឹក(ថ្ងៃទី ១៦ កុម្ភៈ) ជូនមន្ត្រី IT ៤នាក់ មកពីរាជធានី ខេត្ត នីមួយៗ ហើយនឹងចាត់បញ្ជូនក្រុមគ្រូឧទ្ទេសនាមចុះជួយបណ្តុះបណ្តាលបន្ថែមតាមសំណើរបស់គណបក្សរាជធានី ខេត្ត ។ ព្រមជាមួយនេះ ក៏មានការបំពាក់បំប៉នបន្ថែមអំពីការប្រើប្រាស់មុខងារថ្មីមួយចំនួនក្នុងប្រព័ន្ធគ្រប់គ្រងបញ្ជីសមាជិកគណបក្ស ។

## II. **អំពីការផលិតប័ណ្ណសម្គាល់មន្ត្រី និងប័ណ្ណសមាជិកគណបក្សមាន** QR Code

១- ក្នុងដំណើរការរៀបចំប្រព័ន្ធគ្រប់គ្រងបញ្ជីសមាជិកគណបក្ស និងគ្រប់គ្រងមន្ត្រីគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល បានបន្តពិនិត្យរៀបចំឲ្យមាន QR Code នៅលើប័ណ្ណផ្សេងៗ ដែលត្រូវបោះពុម្ពចេញពីប្រព័ន្ធ Server ។ ថ្នាក់ដឹកនាំគណបក្ស និងមន្ត្រីជំនាញ ដែលមានគណនីចូលធ្វើការក្នុងប្រព័ន្ធអាចស្កេន QR Code នៅលើប័ណ្ណដើម្បីពិនិត្យផ្ទៀងផ្ទាត់ជាមួយទិន្នន័យនៅក្នុងប្រព័ន្ធ Server ។

២- យោងតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ការផ្តល់ប័ណ្ណសម្គាល់សមាជិកគណបក្សជាភារកិច្ចរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ បន្ទាប់ពីការធ្វើបញ្ជីសមាជិកគណបក្សតាមប្រព័ន្ធព័ត៌មានវិទ្យា គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលបានបោះពុម្ពប័ណ្ណសម្គាល់សមាជិកគណបក្សចំនួនជាង ៣លានចេញពីប្រព័ន្ធ Server តាមសំណើរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុមការងារគណបក្សចុះមូលដ្ឋាន ។

ទន្ទឹមនឹងការរៀបចំឲ្យមាន QR Code នៅលើប័ណ្ណសម្គាល់សមាជិកគណបក្ស គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលក៏បានរៀបចំដើម្បីបោះពុម្ពប័ណ្ណសម្គាល់សមាជិកគណបក្សជាប័ណ្ណរឹងផងដែរ ។ ដូច្នេះ ប័ណ្ណសម្គាល់សមាជិកគណបក្សមាន ២ប្រភេទ ជាប័ណ្ណក្រដាស និងប័ណ្ណរឹង ។

៣- បន្ទាប់ពីការបញ្ចូលទិន្នន័យមន្ត្រីគណបក្សទៅក្នុងប្រព័ន្ធ Server គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលនឹងត្រៀមរៀបចំដើម្បីបម្រើសំណូមពរនៃការបោះពុម្ពប័ណ្ណសម្គាល់មន្ត្រីគណបក្សគ្រប់ថ្នាក់ចំណុះគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។

ប័ណ្ណសម្គាល់មន្ត្រីគណបក្សដូចខាងលើនេះ ត្រូវប្រើត្រា និងហត្ថលេខាប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ។

សុពលភាពនៃប័ណ្ណសម្គាល់មន្ត្រីគណបក្ស ត្រូវបានកំណត់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ដែលមានរយៈពេលចន្លោះពី ៤-៥ឆ្នាំ ។

៤- តម្លៃបោះពុម្ពប័ណ្ណដែលគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលបានព្រមព្រៀងជាមួយគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត និងក្រុមការងារគណបក្សចុះមូលដ្ឋានអនុវត្តកន្លងមក និងបន្តអនុវត្តរួមមាន ៖

- ប័ណ្ណសមាជិកគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ៣ដុល្លារ
- ប័ណ្ណសម្គាល់មន្ត្រីគណបក្សចំណុះក្រសួង ស្ថាប័ន រាជធានី ខេត្ត ៣ដុល្លារ
- ប័ណ្ណសម្គាល់សមាជិកគណបក្សប្រភេទប័ណ្ណរឹង ៣ដុល្លារ
- ប័ណ្ណសម្គាល់សមាជិកគណបក្សប្រភេទប័ណ្ណក្រដាស ១.២០០រៀល
- សៀវភៅគ្រួសារបក្ស ២.០០០រៀល

៥- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស គណៈកម្មាធិការគណបក្ស ក្រុមការងារគណបក្ស ថ្នាក់ដឹកនាំ និងមន្ត្រីគណបក្សនៅគ្រប់ថ្នាក់ដែលបានផ្តល់ការឧបត្ថម្ភគាំទ្រដល់ដំណើរការនៃប្រព័ន្ធ Server របស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល និងការបោះពុម្ពប័ណ្ណសមាជិកគណបក្ស ចូលរួមចំណែកដ៏ថ្លៃថ្លាក្នុងភារកិច្ចដ៏ឧត្តុង្គឧត្តមរបស់គណបក្សកន្លងមក ហើយសង្ឃឹមថានឹងបានទទួលការគាំទ្រ និងជួយឧបត្ថម្ភដល់ដំណើរការបន្តបន្ទាប់ទៀតនៅលើប្រព័ន្ធ Server នេះ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**សម្តេច ឯកឧត្តម លោកជំទាវ** ប្រធានមេត្តាជ្រាប និងចាត់ចែងដើម្បីចូលរួមសហការអនុវត្តឲ្យសម្រេចបានលទ្ធផលល្អស្របតាមគោលការណ៍របស់គណបក្ស ។

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់!

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល
**គណៈចាត់តាំង**
លេខៈ០៩១/២៤បត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម
ថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៥ខែឧសភា ឆ្នាំ ២០២៤

## គោរព និងជម្រាបជូន

- **សម្តេច ឯកឧត្តម ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល**
- **ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត**
- **ប្រធានក្រុម IT គណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត**

**កម្មវត្ថុ** : អំពីការរៀបចំបន្ថែមកម្មវិធីគ្រប់គ្រងបញ្ជីសមាជិកគណបក្សក្នុងប្រព័ន្ធ Server តាមអង្គការចាត់តាំងគណបក្សចំណុះនីមួយៗ

**យោង** : - សេចក្តីណែនាំលេខ ០០៩/១១២០/សណ.គក ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០២០
- សំណូមពរនៃការងារគ្រប់គ្រងបញ្ជីសមាជិកគណបក្ស
- ស្មារតីអង្គប្រជុំការងារចាត់តាំងកសាងគណបក្សជាមួយគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត តាមប្រព័ន្ធ Zoom នាថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២៤

តាមកម្មវត្ថុ និងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល សូមជម្រាបជូនសម្តេច ឯកឧត្តម លោកជំទាវ ប្រធាន និងក្រុម IT គណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មេត្តាជ្រាបថា ៖

១- បញ្ជីឈ្មោះសមាជិកគណបក្សប្រជាជនកម្ពុជាទាំងអស់ត្រូវបានបញ្ចូលក្នុងប្រព័ន្ធ Server គ្រប់គ្រងដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលដែលត្រូវបានប្រើប្រាស់សម្រាប់ការងារគ្រប់គ្រងកសាងពង្រីកសមាជិកគណបក្ស និងបម្រើឲ្យការងារបោះឆ្នោតកាន់តែមានប្រសិទ្ធភាព ។ បញ្ជីសមាជិកគណបក្សក្នុងប្រព័ន្ធ Server បច្ចុប្បន្ន ធានាបានទិន្នន័យសមាជិកគណបក្សត្រឹមត្រូវតាមអត្តសញ្ញាណប័ណ្ណ និងបញ្ជីបោះឆ្នោត គ្មានឈ្មោះស្ទួន ហើយអាចទាញចេញមកជាតារាងស្ថិតិសមាជិកគណបក្ស ជាបញ្ជីសមាជិកគណបក្សតាមភូមិ តាមក្រុមបក្ស តាមការិយាល័យបោះឆ្នោត បញ្ជីមុខសញ្ញាកសាងបក្សដែលជាប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បញ្ជីមុខសញ្ញាយុវជនអាយុក្រោម ១៨ឆ្នាំ និងបោះពុម្ពប័ណ្ណសម្គាល់សមាជិកគណបក្សមាន QR Code ។

២- តាមសំណើរបស់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីបង្កលក្ខណសម្បត្តិងាយស្រួលដល់ថ្នាក់ដឹកនាំគណបក្ស(ដែលមានគណនី Read Only) អាចពិនិត្យមើលបញ្ជីឈ្មោះ និងស្ថិតិចំនួនសមាជិកគណបក្សតាមអង្គការចាត់តាំងគណបក្សចំណុះនីមួយៗ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលត្រូវរៀបចំបង្កើត Menu បន្ថែមក្នុងប្រព័ន្ធ Server ដែលមានឈ្មោះ គណៈកម្មាធិការគណបក្សមូលដ្ឋាន សាខាគណបក្សចំណុះគ្រប់ថ្នាក់ គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស និងក្រុមសមាជិកចំណុះទាំងអស់ សម្រាប់មន្ត្រីជំនាញ IT ដែលជា Data Entry ជ្រើសរើសបញ្ចូលទិន្នន័យសមាជិកគណបក្ស ទៅតាមអង្គការចាត់តាំងគណបក្សនីមួយៗ ។

៣- ស្នើគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ផ្តល់បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួន មកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីរៀបចំបន្ថែម Menu ក្នុងប្រព័ន្ធ Server សម្រាប់បម្រើការងារដូចបានជម្រាបជូនក្នុងចំណុច ២ ខាងលើនេះ ។

៣.១- បញ្ជីឈ្មោះអង្គការចាត់តាំងចំណុះគណៈកម្មការ ក.២៦ រួមមាន :

- អនុគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ ឧទា. អនុគណៈកម្មការ ក.២៦-០១
- ក្រុមសមាជិកចំណុះអនុគណៈកម្មការនីមួយៗ
- ក្រុមសមាជិកចំណុះតាមបណ្ដាថ្នាក់ (តាមផ្នែក និងកងឯកភាពចំណុះ)

៣.២- បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះក្រសួង ស្ថាប័ន រួមមាន :

- គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះនីមួយៗ
- សាខាគណបក្សចំណុះផ្ទាល់គណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន
- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ (ប្រសិនបើមាន)
- សាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន

៣.៣- បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរាជធានី ខេត្ត រួមមាន :

- គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះនីមួយៗ
- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ
- សាខាគណបក្សចំណុះផ្ទាល់គណៈកម្មាធិការគណបក្សរាជធានី ខេត្ត
- សាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន

៣.៤- បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះក្រុង ស្រុក ខណ្ឌ រួមមាន :

- គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះនីមួយៗ
- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះ
- សាខាគណបក្សចំណុះផ្ទាល់គណៈកម្មាធិការគណបក្សក្រុង ស្រុក ខណ្ឌ
- សាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន

៣.៥- បញ្ជីឈ្មោះសាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សឃុំ សង្កាត់

៤- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាល បានរៀបចំបង្កើត Menu បន្ថែមក្នុងប្រព័ន្ធ Server តាមបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្ស ដែលគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មួយចំនួន ផ្ញើមករួចហើយ ។ ស្នើគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្ដាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ចាត់ចែងផ្ញើបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួនមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលដើម្បីបន្តអនុវត្តការងារតាមស្មារតីដូចបានជម្រាបជូនខាងលើនេះ ។

៥- គណៈចាត់តាំងនៃគណៈកម្មាធិការកណ្ដាលសហការជាមួយគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ដើម្បីរៀបចំទិន្នន័យ ដំឡើង Printer និងផ្ដល់សិទ្ធិជូនក្រសួង ស្ថាប័ន រាជធានី ខេត្ត បោះពុម្ពប័ណ្ណសមាជិកគណបក្សរបស់ខ្លួនចេញពីប្រព័ន្ធ Server តាមសំណូមពរ និងលទ្ធភាពជាក់ស្ដែង ។

សូម**សម្ដេច ឯកឧត្តម លោកជំទាវ** ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត មេត្តាជ្រាប និងសូមមេត្តាចាត់ចែងអនុវត្តតាមការគួរ ។

ដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់!

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**
លេខៈ ០៤២/២៥ ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៤ខែកុម្ភៈ ឆ្នាំ ២០២៥

## គោរព និងជម្រាបជូន
## សម្តេច ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល
## ប្រធានគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត

**កម្មវត្ថុ**: អំពីការគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

**យោង** :
- សេចក្តីណែនាំលេខ ០០១/០១២៥ សណ.គក ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៥
- លិខិតលេខ ០១៤/២៤ ចត.គក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៤
- លិខិតលេខ ០៩១/២៤ ចត.គក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២៤

តាមកម្មវត្ថុនិងយោងខាងលើ គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលសូមគោរព និងជម្រាបជូន អំពីការរៀបចំគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលត្រូវបន្តអនុវត្តដូចខាងក្រោម ៖

១- គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សថ្នាក់កណ្តាល និងគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត បានផ្តល់បញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួនមកគណៈចាត់តាំងនៃគណៈកម្មការកណ្តាល ដើម្បីបញ្ចូលទៅក្នុងកម្មវិធីគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស សម្រេចបានជាមូលដ្ឋានរួចហើយ ។

២- ដើម្បីបង្កលក្ខណសម្បត្តិងាយស្រួលដល់ការគ្រប់គ្រង និងស្វែងរកទិន្នន័យនៅក្នុងប្រព័ន្ធ Server គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាលបានរៀបចំគំនូសបំព្រួញនៃរចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់ ដោយមានកូដសម្គាល់អង្គការចាត់តាំងគណបក្សនីមួយៗ ដូចខាងក្រោម :

- លេខ 1 ជាកូដសម្គាល់ថ្នាក់ក្រសួង ស្ថាប័ន
- លេខ 2 ជាកូដសម្គាល់ថ្នាក់រាជធានី ខេត្ត
- លេខ 3 ជាកូដសម្គាល់ថ្នាក់ក្រុង ស្រុក ខណ្ឌ
- លេខ 4 ជាកូដសម្គាល់ថ្នាក់ឃុំ សង្កាត់
- អក្សរ A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋាន
- អក្សរ B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្ស
- អក្សរ C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ (ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

+ 1A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះក្រសួង ស្ថាប័ន
+ 1B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះក្រសួង ស្ថាប័ន
+ 1C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ក្រសួង ស្ថាប័ន

+ 2A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះរាជធានី ខេត្ត

+ 2B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះរាជធានី ខេត្ត

+ 2C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់រាជធានី ខេត្ត

+ 3A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានចំណុះក្រុង ស្រុក ខណ្ឌ

+ 3B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកគណបក្សចំណុះក្រុង ស្រុក ខណ្ឌ

+ 3C ជាកូដសម្គាល់សាខាគណបក្សចំណុះផ្ទាល់ក្រុង ស្រុក ខណ្ឌ

+ 4C ជាកូដសម្គាល់សាខាគណបក្សចំណុះឃុំ សង្កាត់

+ បន្ទាប់ពីលេខ និងអក្សរជាកូដសម្គាល់ មានលេខរៀង ២ខ្ទង់ នៃអង្គការចាត់តាំងគណបក្សនីមួយៗ

*ចំពោះសាខាគណបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន គឺមានលេខកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋាន និងលេខរៀង ២ខ្ទង់ នៃសាខាគណបក្សចំណុះ

*សាខាគណបក្សភូមិ ដាក់តាមឈ្មោះភូមិនីមួយៗ ដោយមិនមានកូដសម្គាល់ និងលេខរៀងទេ

*ចំពោះភូមិដែលមានសាខាគណបក្សច្រើន ដាក់ឈ្មោះជាសាខាគណបក្សទី ១, ទី ២... និងឈ្មោះភូមិ ។

៣- ស្នើគណៈកម្មាធិការគណបក្សក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រួតពិនិត្យផ្ទៀងផ្ទាត់និងបំពេញបន្ថែមបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សចំណុះរបស់ខ្លួន តាមគំរូរចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សដែលមានកូដសម្គាល់ ជូនភ្ជាប់ជាមួយនេះ ផ្ញើមកគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ដើម្បីកែសម្រួលបំពេញបន្ថែមកម្មវិធីគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធ Server ។ ក្នុងករណី បានផ្ញើបញ្ជីឈ្មោះអង្គការចាត់តាំងគណបក្សមកជាជំហានៗ ឬគ្រប់អស់ហើយ សូមបញ្ជាក់ឡើងវិញអំពីចំនួនសរុបក្នុងបញ្ជីដែលបានផ្ញើមក ។

៤- ការបញ្ចូលទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស ត្រូវបន្តអនុវត្តឱ្យបានសម្រេចតាមគោលការណ៍ណែនាំរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងការណែនាំ បណ្តុះបណ្តាល បំពាក់បំប៉នជំនាញដោយគណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**សម្តេច ឯកឧត្តម លោកជំទាវ**ប្រធានមេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យទទួលបានលទ្ធផលល្អ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សប្រជាជនកម្ពុជា




**ស្ថាប័ន អង្គភាពជំនួយការរបស់គណបក្ស**

១ = ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល
២ = គណៈចាត់តាំង
៣ = គណៈឃោសនាអប់រំ
៤ = គណៈកម្មាធិការត្រួតពិនិត្យ
៥ = គណៈស្រាវជ្រាវប្រវត្តិសាស្ត្រគណបក្ស
៦ = គណៈកម្មាធិការហិរញ្ញវត្ថុ
៧ = គណៈទាក់ទងបរទេស
៨ = គណៈចលនាមហាជន
៩ = យុវជនគណបក្ស
១-១ = មន្ទីរគណបក្ស រាជធានី ខេត្ត ឬ លេខាធិការដ្ឋាន
១-២ = ស្នាក់ការគណបក្សក្រុងស្រុកខណ្ឌ
១-៣ = ស្នាក់ការគណបក្ស ឃុំ សង្កាត់

**បញ្ជាក់** ៤-៦ បោះឆ្នោតជ្រើសតាំងដោយសន្និបាតគណៈកម្មាធិការកណ្តាល ។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់




សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជ. ............ , គណៈកម្មាធិការគណបក្សមដ. ............ , សាខាបក្សចំណុះផ្ទាល់ ............ , សាខាបក្សចំណុះគក.មដ ............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់




សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជ. ............. , គណៈកម្មាធិការគណបក្សមដ. ............. , សាខាបក្សចំណុះផ្ទាល់ ............. , សាខាបក្សចំណុះគក.មដ .............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់

## 3 គណៈកម្មាធិការគណបក្ស ក្រុង/ស្រុក/ខណ្ឌ .................

- **3B គណៈកម្មការគ្រប់គ្រងសមាជិក**
  - 3B01 ឈ្មោះគណៈកម្មការ
    - 3B01.01 ឈ្មោះក្រុមសមាជិក
    - 3B01.02 ឈ្មោះក្រុមសមាជិក
  - 3B02 ឈ្មោះគណៈកម្មការ
    - 3B02.01 ឈ្មោះក្រុមសមាជិក
    - 3B02.02 ឈ្មោះក្រុមសមាជិក
  - 3B03 ឈ្មោះគណៈកម្មការ
    - 3B03.01 ឈ្មោះក្រុមសមាជិក
    - 3B03.02 ឈ្មោះក្រុមសមាជិក
- **គក.គណបក្ស ឃុំ/សង្កាត់**
- **3A គណៈកម្មាធិការគណបក្សមូលដ្ឋាន**
  - 3A01 ឈ្មោះគក.មជ
    - 3A01.01 ឈ្មោះសាខាចំណុះគក.មជ
    - 3A01.02 ឈ្មោះសាខាចំណុះគក.មជ
  - 3A02 ឈ្មោះគក.មជ
    - 3A02.01 ឈ្មោះសាខាចំណុះគក.មជ
    - 3A02.02 ឈ្មោះសាខាចំណុះគក.មជ
  - 3A03 ឈ្មោះគក.មជ
    - 3A03.01 ឈ្មោះសាខាចំណុះគក.មជ
    - 3A03.02 ឈ្មោះសាខាចំណុះគក.មជ
  - 3A04 ឈ្មោះគក.មជ
    - 3A04.01 ឈ្មោះសាខាចំណុះគក.មជ
    - 3A04.02 ឈ្មោះសាខាចំណុះគក.មជ
- **3C សាខាបក្សចំណុះផ្ទាល់**
  - 3C01 ឈ្មោះសាខា
  - 3C02 ឈ្មោះសាខា
  - 3C03 ឈ្មោះសាខា
  - 3C04 ឈ្មោះសាខា

សរុបរួម៖ គណៈកម្មការគ្រប់គ្រងសជ. ............. , គណៈកម្មាធិការគណបក្សមជ. ............. , សាខាបក្សចំណុះផ្ទាល់ ............. , សាខាបក្សចំណុះគក.មជ .............។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សគ្រប់ថ្នាក់

## 4 គណៈកម្មាធិការគណបក្ស ឃុំ/សង្កាត់ ................

### សាខាបក្សភូមិ

- សាខាបក្សភូមិ ...
- សាខាបក្សភូមិ ...
- សាខាបក្សទី១ ភូមិ ...
- សាខាបក្សទី២ ភូមិ ...

### 4C សាខាបក្សចំណុះ

- **4C01** ឈ្មោះសាខា
- **4C02** ឈ្មោះសាខា
- **4C03** ឈ្មោះសាខា
- **4C04** ឈ្មោះសាខា

សរុបរួម៖ សាខាបក្សភូមិ .............. សាខាបក្សចំណុះគណៈកម្មាធិការគណបក្សឃុំ/សង្កាត់ .............។

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

**គណៈចាត់តាំង**
លេខ:១៦៧/២៥ចត.គក

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និងវឌ្ឍនភាពសង្គម

ថ្ងៃសុក្រ ២រោចខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី០៧ខែវិច្ឆិកា ឆ្នាំ ២០២៥

# សេចក្តីណែនាំ
# ស្តីពី
# ការរៀបចំកូដសម្គាល់ ដើម្បីគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគ្រប់ថ្នាក់

**<u>យោង</u>** : - លិខិតលេខ ០៤២/២៥ ចត.គក ចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០២៥ ស្តីពីការគ្រប់គ្រងទិន្នន័យសមាជិកបក្ស-មន្ត្រីគណបក្ស តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគណបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

- ដើម្បីបន្តពង្រឹងការគ្រប់គ្រងទិន្នន័យបញ្ជីសមាជិកបក្សតាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគ្រប់ថ្នាក់ រហូតដល់ក្រុមសមាជិកបក្សនីមួយៗ បម្រើឱ្យការគ្រប់គ្រង កសាងពង្រឹងសមាជិកបក្សទាំងបរិមាណ និងគុណភាព និងការពិនិត្យផ្ទៀងផ្ទាត់ បង្កលក្ខណសម្បត្តិងាយស្រួលដល់ការដឹកនាំសមាជិកបក្សទៅបោះឆ្នោត

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល ណែនាំអំពីការរៀបចំបន្ថែម និងកែសម្រួល កំណត់កូដសម្គាល់បញ្ជីសមាជិកបក្សតាមរចនាសម្ព័ន្ធគណៈកម្មាធិការគណបក្ស គណៈកម្មការគ្រប់គ្រងសមាជិកបក្ស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអង្គការមូលដ្ឋានរបស់គណបក្ស រហូតដល់ក្រុមសមាជិកបក្សនីមួយៗ ដូចខាងក្រោម ៖

## I- <u>ការកំណត់កូដសម្គាល់អង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់</u>

១- កូដសម្គាល់ក្រសួង ស្ថាប័ន ប្រើលេខ ២ ខ្ទង់ ដូចលេខប័ណ្ណសម្គាល់សមាជិកបក្សតាមក្រសួង ស្ថាប័ន ។

២- កូដសម្គាល់រាជធានី ខេត្ត ប្រើលេខ ២ ខ្ទង់ដូចលេខកូដរបស់ គ.ជ.ប ។

៣- កូដសម្គាល់ក្រុង ស្រុក ខណ្ឌ ប្រើលេខ ៤ ខ្ទង់ដូចលេខកូដរបស់ គ.ជ.ប ដែលរួមមានលេខកូដសម្គាល់រាជធានីខេត្ត ២ខ្ទង់ ភ្ជាប់ជាមួយលេខកូដសម្គាល់ក្រុង ស្រុក ខណ្ឌ ២ខ្ទង់ ។

៤- កូដសម្គាល់ឃុំ សង្កាត់ ប្រើលេខ ៥ខ្ទង់ដូចលេខកូដរបស់ គ.ជ.ប ដែលរួមមានលេខកូដសម្គាល់រាជធានី ខេត្ត ២ខ្ទង់ ភ្ជាប់ជាមួយលេខកូដសម្គាល់ឃុំ សង្កាត់ ៣ខ្ទង់ ។

៥- កូដសម្គាល់អង្គការចាត់តាំងគណបក្សចំណុះ ប្រើលេខ និងអក្សរសរុប ៤ខ្ទង់ ដែលរួមមានលេខ ១ខ្ទង់ សម្គាល់ថ្នាក់ក្រសួង ស្ថាប័ន ឬរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ អក្សរសម្គាល់ជាគណៈកម្មាធិការគណបក្សមូលដ្ឋាន ឬគណៈកម្មការគ្រប់គ្រងសមាជិកបក្ស ឬសាខាបក្សចំណុះផ្ទាល់ និងលេខសម្គាល់ ២ខ្ទង់ :

- លេខ ១ ជាកូដសម្គាល់ថ្នាក់ក្រសួង ស្ថាប័ន
- លេខ ២ ជាកូដសម្គាល់ថ្នាក់រាជធានី ខេត្ត
- លេខ ៣ ជាកូដសម្គាល់ថ្នាក់ក្រុង ស្រុក ខណ្ឌ

- អក្សរ A ជាកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋាន
- អក្សរ B ជាកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកបក្ស
- អក្សរ C ជាកូដសម្គាល់សាខាបក្សចំណុះ ។

ឧទាហរណ៍ :

24-1A01 ជាលេខកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានខុទ្ទកាល័យគណៈកម្មាធិការកណ្តាល ចំណុះគណៈកម្មាធិការគណបក្សស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាល ។

24-1C02 ជាលេខកូដសម្គាល់សាខាបក្សគណៈឃោសនាអប់រំ ចំណុះផ្ទាល់គណៈកម្មាធិការគណបក្សស្ថាប័នជុំវិញគណៈកម្មាធិការកណ្តាល ។

12-2A04 ជាលេខកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរអប់រំ យុវជន និងកីឡា ចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

12-2B01 ជាលេខកូដសម្គាល់គណៈកម្មការ ខ.១៨ ចំណុះគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

12-2C01 ជាលេខកូដសម្គាល់សាខាបក្សវិទ្យាល័យបឹងធំ ចំណុះផ្ទាល់គណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ ។

0801-3A01 ជាលេខកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានវិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត ចំណុះគណៈកម្មាធិការគណបក្សស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

0801-3B02 ជាលេខកូដសម្គាល់គណៈកម្មការ ស.២៧ ចំណុះគណៈកម្មាធិការគណបក្សស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

0801-3C01 ជាលេខកូដសម្គាល់សាខាបក្សការិយាល័យសុខាភិបាលប្រតិបត្តិស្រុកកណ្តាលស្ទឹង ចំណុះផ្ទាល់គណៈកម្មាធិការគណបក្សស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

0801 ជាលេខកូដសម្គាល់គណៈកម្មាធិការគណបក្សស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

12005 ជាលេខកូដសម្គាល់គណៈកម្មាធិការគណបក្សសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

## II- ការរៀបចំកូដសម្គាល់សាខាបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន និង អនុសាខា ក្រុមបក្ស

១- កូដសម្គាល់សាខាបក្សចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋាន ប្រើអក្សរ C និងលេខ ២ខ្ទង់ ភ្ជាប់ពីក្រោយកូដសម្គាល់គណៈកម្មាធិការគណបក្សមូលដ្ឋានរបស់ខ្លួន ។

ឧទាហរណ៍:

24-1A01-C02 ជាលេខកូដសម្គាល់សាខាបក្សនាយកដ្ឋានរដ្ឋបាល ចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋានខុទ្ទកាល័យគណៈកម្មាធិការកណ្តាល ។

12-2A04-C01 ជាលេខកូដសម្គាល់សាខាបក្សទី១ ចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ។

12005-C01 ជាលេខកូដសម្គាល់សាខាបក្សភូមិ ១ ចំណុះគណៈកម្មាធិការគណបក្សសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

២- កូដសម្គាល់អនុសាខា ប្រើអក្សរ D និងលេខ ២ខ្ទង់ ភ្ជាប់ពីក្រោយកូដសម្គាល់សាខាបក្សរបស់ខ្លួន ។

ឧទាហរណ៍:

24-1A01-C03-D01 ជាលេខកូដសម្គាល់អនុសាខាទី១ របស់សាខាបក្សនាយកដ្ឋានគ្រប់គ្រង ចំណុះគណៈកម្មាធិការគណបក្សមូលដ្ឋានខុទ្ទកាល័យគណៈកម្មាធិការកណ្តាល ។

12005-C01-D02 ជាលេខកូដសម្គាល់អនុសាខាទី២ របស់សាខាបក្សភូមិ ១ ចំណុះគណៈកម្មាធិការគណបក្សសង្កាត់ដង្កោ រាជធានីភ្នំពេញ ។

៣- កូដសម្គាល់ក្រុមបក្ស ប្រើលេខ ២ (ឬ៣ខ្ទង់) ចាប់ផ្តើមពីលេខ 01 ភ្ជាប់ពីក្រោយកូដសម្គាល់សាខាបក្ស (និងអនុសាខា) របស់ខ្លួន ។ អាចមានភ្ជាប់ទាំងកូដសម្គាល់សាខាបក្ស និងកូដសម្គាល់អនុសាខា ឬមានតែកូដសម្គាល់សាខាបក្ស ។

ឧទាហរណ៍:

12005-C01-D02-01 ជាលេខកូដសម្គាល់ក្រុមបក្សទី១ របស់អនុសាខាទី២ នៃសាខាបក្សភូមិ១ ចំណុះគណៈកម្មាធិការគណបក្សសង្កាត់ដង្កោ រាជធានីភ្នំពេញ ។

02028-C02-15 ជាលេខកូដសម្គាល់ក្រុមបក្សទី១៥ របស់សាខាបក្សភូមិ២ ចំណុះគណៈកម្មាធិការគណបក្សសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

* កំណត់សម្គាល់: ប្រើសញ្ញា " - " ភ្ជាប់ពីលេខកូដសម្គាល់មួយ ទៅលេខកូដសម្គាល់មួយទៀត ។

III- **ការរៀបចំកូដសម្គាល់ក្រុមសមាជិកបក្ស ចំណុះគណៈកម្មការគ្រប់គ្រងសមាជិកបក្ស**

១- កូដសម្គាល់ក្រុមសមាជិកបក្ស ប្រើអក្សរ G និងលេខ ២ខ្ទង់ ភ្ជាប់ពីក្រោយកូដសម្គាល់ក្រសួង ស្ថាប័ន (និងកូដសម្គាល់គណៈកម្មការគ្រប់គ្រងសមាជិកបក្ស) ។

ឧទាហរណ៍:

46-G05 ជាលេខកូដសម្គាល់ក្រុមសមាជិកបក្សទី៥ របស់គណៈកម្មការ ក.១៨

38-1B01-G04 ជាលេខកូដសម្គាល់ក្រុមសមាជិកបក្សទី៤ របស់គណៈកម្មការ ក.២៧០១ ចំណុះគណៈកម្មាធិការគណបក្ស គ.២៧

0203-3B02-G03 ជាលេខកូដសម្គាល់ក្រុមសមាជិកបក្សទី៣ របស់គណៈកម្មការ ស.២៧ ចំណុះគណៈកម្មាធិការគណបក្សក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

២- កូដសម្គាល់អនុគណៈកម្មការ និងក្រុមសមាជិកបក្ស ចំណុះគណៈកម្មការ ក.២៦ ត្រូវបានរៀបចំជា ៣ថ្នាក់ ដូចខាងក្រោម:

- កូដសម្គាល់អនុគណៈកម្មការ ប្រើអក្សរនិងលេខ 1A ឬ 1B ឬ 1C ភ្ជាប់ជាមួយលេខសម្គាល់អនុគណៈកម្មការ
- កូដសម្គាល់ក្រុមសមាជិកបក្ស ចំណុះអនុគណៈកម្មការ ប្រើអក្សរនិងលេខ 2A ឬ 2B ឬ 2C ភ្ជាប់ជាមួយលេខរៀងសម្គាល់ក្រុមសមាជិកបក្ស
- កូដសម្គាល់ក្រុមសមាជិកបក្ស ចំណុះក្រុមសមាជិកបក្សដែលមានក្បាលកូដ 2A ឬ 2B ឬ 2C ប្រើអក្សរនិងលេខ 3A ឬ 3B ឬ 3C ភ្ជាប់ជាមួយលេខរៀងសម្គាល់ក្រុមសមាជិកបក្សរបស់ខ្លួន។

* កំណត់សម្គាល់: អនុគណៈកម្មការមាន ៣ប្រភេទជា អនុគណៈកម្មការ ក អនុគណៈកម្មការ ខ អនុគណៈកម្មការ គ ប្រើកូដជាអក្សរ A ឬ B ឬ C (ជំនួសអក្សរ ក ខ គ)

ដោយឡែក តំបន់ប្រតិបត្តិការសឹករងខេត្តទាំង ២៤ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្តទាំង ២៥ ជាគណៈកម្មការ ខ.២៦ ចំណុះគណៈកម្មាធិការគណបក្សរាជធានី ខេត្ត (តាមគោលការណ៍កំណត់របស់គណបក្ស) ។

ឧទាហរណ៍:

22-1A2601 ជាលេខកូដសម្គាល់អនុគណៈកម្មការ ក.២៦០១ ចំណុះគណៈកម្មការ ក.២៦

22-1A2601-2A1 ជាលេខកូដសម្គាល់នាយកដ្ឋានបុគ្គលិក (1) ចំណុះអនុគណៈកម្មការ ក.២៦០១

22-1A2601-2A8-3A1 ជាលេខកូដសម្គាល់មជ្ឈមណ្ឌលហ្វឹកហ្វឺន... នៃនាយកដ្ឋានបញ្ជូនសារ(8) ចំណុះអនុគណៈកម្មការ ក.២៦០១

22-1B2602-2B1 ជាលេខកូដសម្គាល់ខុទ្ទកាល័យ (1) ចំណុះអនុគណៈកម្មការ ខ.២៦០២

22-1B2602-2B6-3B1 ជាលេខកូដសម្គាល់អង្គភាពសិល្បៈកងទ័ព នៃការិយាល័យទី៥ (6) ចំណុះអនុគណៈកម្មការ ខ.២៦០២

គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល សូមគោរពស្នើសុំ**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** ប្រធានគណៈកម្មាធិការគណបក្ស ប្រធានគណៈកម្មការគ្រប់គ្រងសមាជិកបក្សគ្រប់ថ្នាក់ មេត្តាចូលរួមសហការចាត់ចែងអនុវត្តការងារដូចខាងលើនេះឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ ។

**ប្រធានគណៈចាត់តាំង**

**សោម សឿន**

## តារាងសង្ខេបរៀបចំកូដសម្គាល់ តាមរចនាសម្ព័ន្ធ អង្គការចាត់តាំងគ្រប់ថ្នាក់

| គណៈកម្មាធិការគណបក្ស | កូដសម្គាល់អង្គការចាត់តាំង | គណៈកម្មាធិការគណបក្ស មូលដ្ឋាន និងសាខាចំណុះ | | គណៈកម្មការ គ្រប់គ្រង និងក្រុមសមាជិក | | សាខាគណបក្ស ចំណុះផ្ទាល់ | អនុសាខា គណបក្ស | លេខកូដ ក្រុមបក្ស |
|---|---|---|---|---|---|---|---|---|
| ថ្នាក់ក្រសួង ស្ថាប័ន | លេខកូដប័ណ្ណ ២ខ្ទង់ (00-) | 1A00- | C00- | 1B00- | G00 | 1C00- | D00- | 00 |
| ថ្នាក់រាជធានី ខេត្ត | លេខកូដគ.ជ.ប ២ខ្ទង់ (00-) | 2A00- | C00- | 2B00- | G00 | 2C00- | D00- | 00 |
| ថ្នាក់ក្រុង ស្រុក ខណ្ឌ | លេខកូដគ.ជ.ប ៤ខ្ទង់ (0000-)<br>លេខកូដរាជធានី ខេត្ត ២ខ្ទង់<br>និងក្រុង ស្រុក ខណ្ឌ ២ខ្ទង់ | 3A00- | C00- | 3B00- | G00 | 3C00- | D00- | 00 |
| ថ្នាក់ឃុំ សង្កាត់ | លេខកូដគ.ជ.ប ៥ខ្ទង់ (00000-)<br>លេខកូដរាជធានី ខេត្ត ២ខ្ទង់<br>និងឃុំ សង្កាត់ ៣ខ្ទង់ | | | | | C00- | D00- | 00 |

| | កូដសម្គាល់អង្គការចាត់តាំង | អនុគណៈកម្មការ | | ក្រុមសមាជិក អនុគណៈកម្មការ | ក្រុមសមាជិក ចំណុះឲ្យ ក្រុមសមាជិកអនុគណៈកម្មការ | លេខកូដ ក្រុមសជិ. |
|---|---|---|---|---|---|---|
| គណៈកម្មការ ក.២៦ | 22- | **ក.២៦** | 1A2600- | 2A0- | 3A0- | G00 |
| | 22- | **ខ.២៦** | 1B2600- | 2B0- | 3B0- | G00 |
| | 22- | **គ.២៦** | 1C2600- | 2C0- | 3C0- | G00 |